អង្គការសហប្រជាជាតិ

មហាសន្និបាត

ចែកចាយៈ ទូទៅ

០២ សីហា ឆ្នាំ២០១១

ច្បាប់ដើមៈ ភាសាអង់គ្លេស

**ក្រុមប្រឹក្សាសិទ្ធិមនុស្ស**

**សម័យប្រជុំលើកទីដប់ប្រាំបី**

របៀបវារៈចំណុចទី១០

**ស្ថានភាពសិទ្ធិមនុស្សដែលតម្រូវឲ្យក្រុមប្រឹក្សាសិទ្ធិមនុស្សចិត្តទុកដាក់**

# របាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា

លោកសាស្ត្រាចារ្យ **សុរិយា ប្រាសាទ ស៊ូប៊ែឌី**

*សេចក្ដីសង្ខេប*

ឆ្នាំនេះគឺជាខួបលើកទី២០ នៃការអនុម័តកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១ ដែលផ្ដើមដំណើរការសន្តិភាពនៅកម្ពុជា។ អាណត្តិរបស់អ្នករាយការណ៍ពិសេសមានប្រភពកើតចេញពីកិច្ចព្រមព្រៀងទាំងនេះ។ តាមរយៈកិច្ចព្រមព្រៀងនេះ កម្ពុជាបានសំរេចសមិទ្ធិផលធំធេងជាច្រើនក្នុងវិស័យផ្សេងៗ។ ប៉ុន្តែទោះជាដូច្នេះក្ដី កម្ពុជានៅមានដំណើរផ្លូវមួយវែងឆ្ងាយទៀត ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ក្រោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងឡាយដែលកម្ពុជាបានផ្ដល់សច្ចាប័នទទួលយក។ សហគមន៍អន្តរជាតិ គួរតែបន្តជួយដល់ប្រទេសកម្ពុជាក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីបង្កើតនីតិរដ្ឋ និងការស្ដាបនាឡើងវិញនូវស្ថាប័នរដ្ឋសំខាន់ៗ ។

អ្នករាយការណ៍ពិសេសមានកង្វល់ជាពិសេស អំពីស្ថានភាពនៃបញ្ហាសិទ្ធិមនុស្សផ្សេងៗ ជាពិសេស សេរីភាពខាងការបញ្ចេញមតិ សិទ្ធិដីធ្លី និង សិទ្ធិលំនៅដ្ឋាន។ លោកយល់ឃើញថា គេមិនគួរយកក្រមព្រហ្មទណ្ឌទៅអនុវត្តលើសិទ្ធិបញ្ចេញមតិដោយសន្តិវិធីនោះទេ បច្ចុប្បន្ននេះ ករណីបែបនេះ មានជាអាទិ៍ ការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិត។ អ្នករាយការណ៍ពិសេស មានកង្វល់ផងដែរអំពីលំហរតូចចង្អៀត



Please recycle

សំរាប់ប្រជាជនក្នុងការបញ្ចេញមតិយោបល់របស់ខ្លួនដោយសន្តិវិធី និងដោយគ្មានការភ័យខ្លាច រាប់ទាំងសកម្មជនក្នុងគណៈបក្សនយោបាយផ្សេងៗ។ លោកមានកង្វល់ជាពិសេសក្នុងបញ្ហានេះអំពីករណីនៃការចោទប្រកាន់ពីបទញុះញង់ បទបរិហារកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិត ប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស សកម្មជនខាងសិទ្ធិដីធ្លី និងសមាជិកសហគមន៍នានា ដែលការពារសិទ្ធិដីធ្លី និង សិទ្ធិលំនៅដ្ឋានរបស់ខ្លួនដែលកំពុងប្រឈមនឹងការបណ្តេញចេញ។

កម្ពុជាបានអនុម័តច្បាប់មួយចំនួន ដែលមានគោលដៅការពារសិទ្ធិមនុស្ស ប៉ុន្តែការអនុវត្តន៍ច្បាប់ទាំងនោះ នៅមានភាពចន្លោះប្រហោងជាច្រើន។ ច្បាប់ជាច្រើនដែលសភាបានអនុម័ត និងបទបញ្ញាផ្ទៃក្នុងរបស់ខ្លួន មិនទាន់ស្របតាមបទដ្ឋានដែលបានកំណត់ក្នុងគោលការណ៍នីតិរដ្ឋនៅឡើយទេ។ អ្វីដែលកម្ពុជាយកធ្វើជាឧត្តមានុភាពនៅក្នុងវិស័យជាច្រើននោះគឺ ការបង្កើតច្បាប់សំរាប់គ្រប់គ្រង ច្រើនជាងការប្រតិបត្តិច្បាប់ដែលមានស្រាប់(នីតិរដ្ឋ)។

របាយការណ៍នេះផ្តោតលើការវាយតំលៃអំពីឯករាជ្យភាព និងសមត្ថភាពរបស់សភាដែលជាស្ថាប័នរដ្ឋមួយក្នុងចំណោមស្ថាប័នរដ្ឋឯទៀត ដែលទទួលខុសត្រូវក្នុងការលើកស្ទួយសិទ្ធិប្រជាពលរដ្ឋ។ ម្យ៉ាងវិញទៀត គោលការណ៍បែងចែកអំណាចមានភាពទន់ខ្សោយហើយគេសង្កេតឃើញថាសមត្ថភាពរបស់សភានៅមានកំរិតនៅឡើយក្នុងការដើរតួនាទីជាអ្នកពិនិត្យប្រកបដោយប្រសិទ្ធភាពលើសកម្មភាពការងាររបស់ស្ថាប័នប្រតិបត្តិ។

សភាជាដួងព្រលឹងនៃលិទ្ធិប្រជាធិបតេយ្យ និង ជាអ្នកទទួលខុសត្រូវក្នុងការអនុម័តច្បាប់ចាំបាច់ ដើម្បីការពារសិទ្ធិមនុស្ស។ ផ្អែកលើស្មារតីនេះ អ្នករាយការណ៍ពិសេស ផ្តល់ជាអនុសាសន៍បន្តបន្ទាប់នៅក្នុងរបាយការណ៍នេះ ក្នុងន័យស្ថាបនា ហើយសង្ឃឹមថារាជរដ្ឋាភិបាល សភា និង អ្នកពាក់ព័ន្ធឯទៀតនឹងអនុវត្តតាមអនុសាសន៍ទាំងនេះ។

មាតិការឿង


| | | *កថាខណ្ឌ* | *ទំព័រ* |
|---|---|---|---|
| **I.** | **សេចក្តីផ្តើម** | ១ - ៤ | ៤ |
| **II.** | **ពិធីសាស្ត្រ និង ទិសដៅការងារ** | ៥ - ៦ | ៥ |
| **III.** | **ស្ថានការណ៍វិវត្តន៍ថ្មីៗក្នុងវិស័យសិទ្ធិមនុស្ស** | ៧ - ៣៥ | ៦ |
| | ក. សិទ្ធិដីធ្លី និង សិទ្ធិលំនៅដ្ឋាន | ៨ - ១៧ | ៦ |
| | ខ. សេរីភាពខាងការបញ្ចេញមតិ | ១៨ - ២៤ | ១១ |
| | គ. សេចក្តីព្រាងច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល | ២៥ - ៣១ | ១៥ |
| | ឃ. សេចក្តីព្រាងច្បាប់ស្តីពីសហជីពកម្មករ | ៣២ - ៣២ | ១៨ |
| | ង. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(ECCC) | ៣៣ - ៣៥ | ១៩ |
| **IV.** | **តួនាទី និង ប្រសិទ្ធភាពរបស់សភាក្នុងការការពារសិទ្ធិមនុស្ស** | ៣៦ - ៥៤ | ២០ |
| | ក. រចនាសម្ព័ន្ធទូទៅរបស់សភា | ៣៦ - ៤០ | ២០ |
| | ខ. ប្រសិទ្ធភាពរបស់ព្រឹទ្ធសភា | ៤១ -៤១ | ២១ |
| | គ. ប្រសិទ្ធភាពរបស់រដ្ឋសភា | ៤២ - ៤៩ | ២២ |
| | ឃ. ការការពារសេរីភាពក្នុងការនិយាយស្តីរបស់សមាជិកសភា | ៥០ - ៥៤ | ២៥ |
| **V.** | **ក្រុមប្រឹក្សាធម្មនុញ្ញ សិទ្ធិមនុស្ស និង សភា** | ៥៥ - ៥៨ | ២៨ |
| **VI.** | **សេចក្តីសន្និដ្ឋាន** | ៥៩ - ៦៣ | ៣០ |
| **VII.** | **អនុសាសន៍ផ្សេងៗ** | ៦៤ - ៩៣ | ៣២ |
| | ក. ទិដ្ឋភាពទូទៅ - សភា | ៦៤ - ៦៥ | ៣២ |
| | ខ. ការពង្រឹងសមត្ថភាព និង ការងាររបស់សភា | ៦៦ - ៨០ | ៣៣ |
| | គ. ការបង្កើនប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាធម្មនុញ្ញ | ៨១ - ៨៥ | ៣៥ |
| | ឃ. សភា និង សេរីភាពខាងការបញ្ចេញមតិ | ៨៦ - ៨៧ | ៣៦ |
| | ង. សេរីភាពខាងការបញ្ចេញមតិ | ៨៨ - ៨៨ | ៣៦ |
| | ច. សិទ្ធិដីធ្លី | ៨៩ - ៩៣ | ៣៧ |

# I. សេចក្តីផ្តើម

១. នេះជារបាយការណ៍ទីបី របស់អ្នករាយការណ៍ពិសេសបច្ចុប្បន្ន ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ដែលបានដាក់ស្នើស្របតាមសេចក្តីសំរេចរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស លេខ ១៥/២០ ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១០។

២. កម្ពុជា បានសំរេចសមិទ្ធិផលដ៏ធេងនៅក្នុងវិស័យជាច្រើន ចាប់តាំងពីការចុះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសមក ដែលនេះជាប្រការមួយគួរឲ្យស្ញើចសរសើរ។ ជម្លោះត្រូវបានដោះស្រាយ សម័យអន្តរកាលត្រូវបានគ្រប់គ្រងបានល្អប្រសើរ រដ្ឋធម្មនុញ្ញថ្មីមួយបែបប្រជាធិបតេយ្យ ត្រូវបានអនុម័តក្នុងឆ្នាំ១៩៩៣ ហើយបានរៀបចំឲ្យមានការបោះឆ្នោតតាមកាលកំណត់ជាហូរហែរ ចាប់តាំងពីពេលនោះរហូតមក។ សេដ្ឋកិច្ចមានការរីកលូតលាស់ជាលំដាប់ ហើយស្ថិរភាពនយោបាយនៅក្នុងអំឡុងកាលប៉ុន្មានឆ្នាំថ្មីៗនេះអាចឲ្យប្រជាជនជាច្រើនចាកផុតពីភាពក្រីក្រ យ៉ាងហោចណាស់ក៏នៅតំបន់ទីប្រជុំជនដែរ។

៣. កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស បានបង្កើតឲ្យមាននីតិរដ្ឋ សិទ្ធិមនុស្ស និងលិទ្ធិប្រជាធិបតេយ្យ ដែលជាសរសរទ្រូងដ៏សំខាន់បំផុត សំរាប់ការរៀបចំរចនាសម្ព័ន្ធនយោបាយថ្មីនៅប្រទេសនេះ។ ហេតុដូច្នេះ សហគមន៍អន្តរជាតិមានការសន្យា និង ការទទួលខុសត្រូវមួយជាក់លាក់នៅក្នុងបញ្ហានេះ។ ដោយសារតែបរិបទនេះហើយ ទើបអ្នករាយការណ៍ពិសេសបានយល់ព្រមជាមួយរាជរដ្ឋាភិបាល ក្នុងការធ្វើការវាយតំលៃជាប្រព័ន្ធអំពីស្ថាប័នរដ្ឋនានា ក្នុងគោលដៅរិះរកវិធីសាស្រ្ត និងមធ្យោបាយផ្សេងៗ ដើម្បីពង្រឹងសមត្ថភាព និង ឯករាជ្យភាពរបស់ស្ថាប័នទាំងនោះ ក្នុងការលើកស្ទួយសិទ្ធិប្រជាពលរដ្ឋ។ ហេតុដូច្នេះ របាយការណ៍លើកមុនរបស់អ្នករាយការណ៍ពិសេស (A/HRC/15/46) បានផ្តោតជាសំខាន់លើប្រព័ន្ធយុត្តិធម៌ ហើយរបាយការណ៍លើកនេះបានផ្តោតលើតួនាទី និងការប្រព្រឹត្តទៅរបស់សភា។ ក្នុងដំណើរបេសកកម្មពីរលើកកន្លងមករបស់លោកនៅកម្ពុជា ក្នុងឆ្នាំ២០១១ អ្នករាយការណ៍ពិសេសបានផ្តោតជាសំខាន់លើការពិនិត្យអំពីសមត្ថភាព របស់សភាក្នុងការលើកស្ទួយសិទ្ធិប្រជាពលរដ្ឋ និងបទដ្ឋានប្រជាធិបតេយ្យ។

៤. អ្នករាយការណ៍ពិសេស មានក្តីសោមនស្សរីករាយដោយឃើញថា រដ្ឋាភិបាលបានឆ្លើយតបជាវិជ្ជមាន ក្នុងការពន្លឿនកម្មវិធីនីតិកម្មរបស់ខ្លួន ដែលបានតាក់តែងឡើងដើម្បីអនុវត្ត ក្នុងចំណោមអនុសាសន៍ឯទៀត អនុសាសន៍គន្លឹះសំខាន់ៗរបស់អ្នករាយការណ៍ពិសេសទាក់ទងនឹងប្រព័ន្ធយុត្តិធម៌។ រដ្ឋាភិបាលបានបញ្ជាក់ថា អនុសាសន៍ទាំងឡាយដែលអ្នករាយការណ៍ពិសេសបានធ្វើនៅក្នុងរបាយការណ៍លើកមុនរបស់លោក កំពុងត្រូវ

បានអនុវត្ត ឬកំពុងដំណើរការរៀបចំធ្វើផែនការសំរាប់អនុវត្ត។ ជាអាទិ៍ អ្នករាយការណ៍ពិសេស មានការពេញចិត្តចំពោះការគូសបញ្ជាក់ថា ច្បាប់រៀបចំអង្គការដែលបានអូសបន្លាយពេលដ៏យូរមកហើយនោះស្តីពីប្រព័ន្ធយុត្តិធម៌ នៅទីបំផុត ក៏កំពុងដំណើរការទៅមុខដែរ។ គួរកត់សំគាល់ដែរថា ក្រុមការងារអន្តរក្រសួងមួយ ត្រូវបានបង្កើតឡើង ដើម្បីធ្វើកិច្ចការនេះ។ ទោះជាដូច្នេះក្តី រដ្ឋាភិបាលនៅមិនទាន់បានឆ្លើយតបតាមការស្នើរបស់អ្នករាយការណ៍ពិសេស សុំឲ្យកំណត់ក្របខ័ណ្ឌពេលវេលាមួយជាក់លាក់ ឬ ផែនការសកម្មភាពមួយច្បាស់លាស់ ដើម្បីអនុវត្តអនុសាសន៍គន្លឹះសំខាន់ៗរបស់គាត់ទេ។

## II. *ពិធីសាស្ត្រ និង ទិសដៅការងារ*

៥. នៅក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ អ្នករាយការណ៍ពិសេស បានបំពេញបេសកកម្មចំនួនពីរលើកនៅកម្ពុជា ក្នុងឆ្នាំ២០១១ ពីថ្ងៃទី១៥ ដល់ថ្ងៃទី២៥ ខែកម្ភៈ និងពីថ្ងៃទី៣០ ខែឧសភា ដល់ថ្ងៃទី៩ ខែមិថុនា។ លោកសូមថ្លែងអំណរគុណដល់រដ្ឋាភិបាលចំពោះកិច្ចសហការល្អ នៅក្នុងពេលបំពេញបេសកកម្មរបស់លោក និងបង្ហាញអំពីចេតនាធ្វើការជាមួយគាត់ប្រកបដោយន័យស្ថាបនា។ ក្នុងអំឡុងពេលបំពេញបេសសកម្មរបស់លោក អ្នករាយការណ៍ពិសេសបានផ្តោតជាសំខាន់លើតួនាទី និងការប្រព្រឹត្តទៅរបស់សភា។ អ្នករាយការណ៍ពិសេស មានបុព្វសិទ្ធចូលជួបពិភាក្សាការងារជាមួយឯកឧត្តម នាយករដ្ឋមន្ត្រី ហ៊ុន សែន ឯកឧត្តម ហេង សំរិន ប្រធានរដ្ឋសភា ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សុខ អាន និងសមាជិកជាន់ខ្ពស់ដទៃទៀតរបស់រដ្ឋាភិបាល ព្រមទាំងសមាជិកមួយចំនួននៃព្រឹទ្ធសភា និងរដ្ឋសភា មកពីគណបក្សនយោបាយផ្សេងៗ។[1] លោកមានការពេញចិត្តចំពោះការឆ្លើយតបរបស់មន្ត្រីទាំងឡាយចំពោះបញ្ហាមួយចំនួន ដែលលោកបានលើកជាសំណួរ។ អ្នករាយការណ៍ពិសេស ត្រូវបានសង្ខេបប្រាប់ឲ្យដឹងអំពីការងារផ្សេងៗដែលសភាទាំងពីរបាននិងកំពុងធ្វើ ដើម្បីពិនិត្យគណនីយភាពរបស់អង្គនីតិប្រតិបត្តិ និងក្នុងការការពារ និងការលើកស្ទួយសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។ លោកបានវាយតំលៃខ្ពស់ចំពោះច្បាប់ថ្មីមួយចំនួនដែលសភាបានអនុម័តក្នុងវិស័យនេះ។ អ្នករាយការណ៍ពិសេស បានសង្កេតឃើញមានចន្លោះប្រហោងជាច្រើនក្នុងការប្រព្រឹត្តទៅរបស់សភា ហើយបានផ្តល់ជូនជាអនុសាសន៍មួយចំនួន ដើម្បីដោះស្រាយបញ្ហាទាំងនោះដែលមានសរសេរនៅផ្នែកខាងចុងបញ្ចប់នៃរបាយការណ៍នេះ។

[1] គួរឲ្យសោកស្តាយដែលអ្នករាយការណ៍ពិសេសមិនមានឱកាសជួបជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៅពេលកន្លងមក។

៦. អ្នករាយការណ៍ពិសេស បានជួបប្រជុំ ដាច់ដោយឡែក ជាមួយក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា និងសមាជិករបស់ខ្លួន អង្គការផ្តល់ជំនួយនានា អ្នកការទូត និងបានធ្វើទស្សនកិច្ចទៅកាន់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(ECCC) ដែលនៅទីនោះ លោកបានជួបប្រជុំរយៈពេលខ្លីជាមួយប្រធាន និង អនុប្រធានអង្គជំនុំជម្រះពេញអង្គនៃសាលាក្តីនេះ នៅមុនពេលបិទសម័យប្រជុំលើកទីប្រាំពីររបស់ខ្លួន។ លោកបានជួបផងដែរជាមួយជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្ស រាប់ទាំងក្រុមជនជាតិដើមភាគតិច និង សហគមន៍ទាំងឡាយដែលរងផលប៉ះពាល់ដោយការបណ្តេញចេញពីដីធ្លី ក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ និង បានជួបពិភាក្សាផ្ទាល់ជាមួយបុគ្គលដែលរងការចោទប្រកាន់ពីបទញុះញង់ និង បានធ្វើអន្តរកម្មជាមួយតំណាងសហជីពកម្មករ និងអង្គការសង្គមស៊ីវិលមួយចំនួន ដែលធ្វើការក្នុងវិស័យសិទ្ធិមនុស្ស កំណែទម្រង់សភា និងវិស័យសិទ្ធិមនុស្សធំៗឯទៀត មានជាអាទ៍ សិទ្ធិដីធ្លី និង សេរីភាពខាងការបញ្ចេញមតិ ព្រមទាំង ប្រជាពលរដ្ឋជាឯកត្តបុគ្គលផ្សេងៗ។ លោកបានធ្វើទស្សនកិច្ចទៅកាន់ខេត្តកំពង់ឆ្នាំង តំបន់បឹងកក់ និង ខណ្ឌសែនសុខ ដែលនៅទីនោះមានគ្រួសារប្រជាពលរដ្ឋមួយចំនួនកំពុងប្រឈមនឹងការគំរាមបណ្តេញចេញ ឬត្រូវបានគេបង្ខំឲ្យរើចេញពីទីនោះ។

## III. *ស្ថានការណ៍វិវត្តន៍ថ្មីៗក្នុងវិស័យសិទ្ធិមនុស្ស*

៧. ទន្ទឹមនឹងស្ថានភាពទូទៅផ្នែកសិទ្ធិមនុស្សមានការរីកចំរើនក្នុងវិស័យខ្លះក្តី ក៏ក្នុងវិស័យដទៃផ្សេងទៀត នៅមិនទាន់មានការរីកចំរើនច្រើននៅឡើយដែរ។

### ក. *សិទ្ធិដីធ្លី និង សិទ្ធិលំនៅដ្ឋាន*

៨. ទំនាស់ដីធ្លីនៅតែបន្តប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជាច្រើន នៅតំបន់ជនបទ ជាពិសេស ប្រជាពលរដ្ឋក្រីក្រដែលគេមិនសូវគិតគូរ ហើយមិនមានយន្តការមានប្រសិទ្ធភាពណាមួយ ដើម្បីដោះស្រាយការប្តឹងតវ៉ារបស់ពួកគាត់ឡើយ។ ខណៈដែលរដ្ឋាភិបាលកំពុងបង្កើតគោលនយោបាយមួយចំនួនសំរាប់គ្រប់គ្រងដីធ្លី លំនៅដ្ឋាន និងការតាំងទីលំនៅថ្មី ក៏ដំណើរការនេះមានការរីកចំរើនយឺត។ ទំនាស់ដីធ្លីជាច្រើននៅមិនទាន់បានដោះស្រាយនៅឡើយ ទំនាស់ដីធ្លីមួយចំនួនក្នុងនោះ ត្រូវបានជ្រៀតជ្រែករំខានដោយអំពើពុករលួយ បន្តនាំឲ្យមានការប៉ះទង្គិចគ្នារវាងរដ្ឋាភិបាល សង្គមស៊ីវិល និងសហគមន៍នានា ក្រោមការគំរាមបណ្តេញចេញដោយបង្ខំ និងជាដើមចមនៃការផ្ទុះឡើងនៃអំពើហឹង្សានៅក្នុងអំឡុងពេលប៉ុន្មានខែកន្លងទៅថ្មីៗនេះ។

៩. ប្រព័ន្ធយុត្តិធម៌ មិនមានប្រសិទ្ធភាពក្នុងការលើកស្ទួយសិទ្ធិប្រជាពលរដ្ឋជាច្រើន ដែលរងផលប៉ះពាល់ដោយការគ្មានប័ណ្ណកម្មសិទ្ធិដីធ្លី។ យន្តការដែលមានស្រាប់សំរាប់ដោះស្រាយទំនាស់ដីធ្លីបច្ចុប្បន្ននេះ មានជាអាទិ៍ គណៈកម្មការសុរិយោដី និងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(NALDR) ត្រូវបានគេរាយការណ៍ថា ខ្វះធនធាន និងមិនមានប្រសិទ្ធភាព ក្នុងការលើកកំពស់សិទ្ធិអ្នកកាន់កាប់ដីធ្លីដែលមានទំហំតូចៗ ហើយសហគមន៍ខ្លះរាយការណ៍ថា ពួកគាត់ចង់បានការដោះស្រាយទំនាស់ តាមយន្តការក្រៅប្រព័ន្ធតុលាការ ដោយសារពួកគាត់មិនមានការជឿជាក់លើតុលាការ និងប្រព័ន្ធដែលមានស្រាប់សំរាប់ដោះស្រាយទំនាស់ដីធ្លីបច្ចុប្បន្ននេះ។ ក្នុងអំឡុងពេលធ្វើរបាយការណ៍នេះ មានជំនាស់ដីធ្លីមួយចំនួនកំពុងរីកសាយធំឡើង ហើយប្រជាពលរដ្ឋមួយចំនួនធំ ត្រូវបានគេបណ្តេញចេញពីដីធ្លីរបស់ខ្លួន ឬបានប្រឈមនឹងការគំរាមបណ្តេញចេញ ដោយបង្ខំ ទោះជាគេបានប្រើប្រាស់អស់មធ្យោបាយតាមផ្លូវច្បាប់ ដើម្បីដោះស្រាយទំនាស់ដោយសន្តិវិធី ឬ ទទួលបានការដោះស្រាយមួយសមរម្យហើយក្តី។

១០. ប្រជាពលរដ្ឋយ៉ាងហោចណាស់ក៏ ៣,០០០ ទៅ ៤,០០០ គ្រួសារដែរ ដែលកំពុងរស់នៅជុំវិញតំបន់បឹងកក់ ត្រូវបានបណ្តេញចេញ ឬកំពុងប្រឈមនឹងការគំរាមបណ្តេញចេញដោយបង្ខំពីលំនៅដ្ឋានរបស់ខ្លួន ចាប់តាំងពីពេលដែលរដ្ឋាភិបាលបានចុះកិច្ចសន្យាជួលទីតាំងនោះរយៈពេល ៩៩ ឆ្នាំទៅឲ្យក្រុមហ៊ុនស៊ូកាគូ សំរាប់ការអភិវឌ្ឍន៍ដីនៅតំបន់នោះ។ គេបានបំភិតបំភ័យ និងគំរាមអ្នកភូមិ បង្ខំឲ្យពួកគាត់យល់ព្រមទទួលយកសំណងតិចតួចបំផុត ឬ ជាថ្នូរនឹងការតាំងទីលំនៅថ្មីនៅខាងក្រៅរាជធានីភ្នំពេញ បើទោះជាមានអ្នកភូមិជាច្រើនបានទាមទារយ៉ាងខ្លាំងក្លា សុំឲ្យចេញប័ណ្ណកម្មសិទ្ធិដីធ្លីផ្លូវការ ស្របតាមមាត្រា៣០ និងមាត្រា៣១ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ ក្តី។ កម្លាំងសន្តិសុខបានធ្វើការបំភិតបំភ័យ និងប្រើអំពើហឹង្សាផងដែរ ប្រឆាំងនឹងអ្នកតវ៉ា។ ចាប់តាំងពីឆ្នាំ២០០៨ មកក្រុមហ៊ុនស៊ូកាគូ បានផ្តើមដំណើរការបូមខ្សាច់ចាក់បំពេញបឹងនោះ ហើយមានគ្រួសារជាច្រើនបានរុះរើផ្ទះសម្បែងរបស់ខ្លួនចេញពីតំបន់នោះ ដោយការព្រមទទួលយកកញ្ចប់សំណងជាថវិកាតិចតួចស្តួចស្តើងបំផុត ស្ថិតនៅចំពោះមុខការគំរាមបណ្តេញចេញដោយបង្ខំជាយថាហេតុនេះ។ ទោះជាយ៉ាងណាក៏ដោយ តាមការប៉ាន់ស្មានមានប្រជាពលរដ្ឋប្រមាណជា ១៥០០ គ្រួសារ កំពុងប្រឈមនឹងការគំរាមបណ្តេញចេញដោយបង្ខំ។ ទន្ទឹមនឹងមានការរៀបចំឲ្យមានកិច្ចពិភាក្សាគ្នា រវាងសហគមន៍រងផលប៉ះពាល់នៅតំបន់បឹងកក់ និងសាលារាជធានីភ្នំពេញក្តី ក៏ករណីនេះ នៅមិនទាន់មានការព្រមព្រៀងគ្នាជាដុំកំភួននៅឡើយទេ លើបញ្ហាសំណង និងការដោះស្រាយការស្នើរបស់អ្នកភូមិសុំអភិវឌ្ឍន៍នៅនឹងកន្លែង។

១១. ដោយមានការជួយឧបត្ថម្ភពីសហគមន៍អន្តរជាតិ រដ្ឋាភិបាលបានផ្តើមអនុវត្តកម្មវិធីពង្លឿនការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លីនៅក្នុងប្រទេស ដែលបើទោះជាដូច្នេះក្តី កិច្ចដំណើរការនេះ ជារឿយៗ មិនមានតម្លាភាពទេ ទាក់ទងនឹងសម្បទានដីសេដ្ឋកិច្ច។ ការទន្ទ្រានកាន់កាប់ដីធ្លីដោយបុគ្គលមួយចំនួន ដែលជាអ្នកមានទ្រព្យសម្បត្តិ និងអ្នកមានអំណាចបានកើតមានក្នុងពេលដំណើរការផ្តល់ប័ណ្ណកម្មសិទ្ធិដីធ្លី។ ទន្ទឹមនឹងការផ្តល់សម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច សំរាប់គោលដៅផលប្រយោជន៍សាធារណៈស្របច្បាប់ ករណីដូចនេះ មិនត្រូវបានគេនិយាយដល់សម្បទានមួយចំនួនផ្សេងទៀតនោះទេ។

១២. ម្យ៉ាងវិញទៀត បុគ្គលទាំងឡាយដែលតស៊ូមតិដើម្បីសិទ្ធិសហគមន៍របស់ខ្លួនលើដីធ្លី ជារឿយៗ ត្រូវបានចាប់ខ្លួនតាមទំនើងចិត្ត និងត្រូវបានចោទប្រកាន់ដោយគ្មានមូលដ្ឋាន។ កង្វះការសន្ទនា និងការពិគ្រោះយោបល់ជាមួយសហគមន៍ទាំងឡាយដែលត្រូវរងផលប៉ះពាល់ មុនការផ្តល់សម្បទានដីសេដ្ឋកិច្ចនោះ គឺជាលំនាំដ៏អកុសលមួយដែលអ្នករាយការណ៍ពិសេសបានសង្កេតឃើញ ក៏ដូចជា ការខកខានមិនបានធ្វើការវាយតំលៃអំពីហេតុប៉ះពាល់បរិស្ថាន។ អ្នករាយការណ៍ពិសេស បានសង្ឃឹមនៅក្នុងរបាយការណ៍របស់គាត់កាលពីឆ្នាំទៅថា រដ្ឋាភិបាលនឹងបង្កើតឲ្យមានយន្តការមួយ រួមគ្នាជាមួយអង្គការមិនមែនរដ្ឋាភិបាលនានា ក្នុងកិច្ចខិតខំប្រឹងប្រែងដោះស្រាយបញ្ហាកើនឡើងនៃចំនួនទំនាស់ដីធ្លី ហើយលោកមានការពេញចិត្ត ចំពោះការប្រកាសរបស់ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ក្នុងការបង្កើតឲ្យមានយន្តការមួយនេះ នៅក្នុងខែឧសភា ឆ្នាំ២០១១។

១៣. អ្នករាយការណ៍ពិសេសបានសង្កេតឃើញ និន្នាការមួយដែលបានស្តែងឲ្យឃើញពីការរួមបញ្ចូលបរិធានរដ្ឋជាមួយផលប្រយោជន៍ពាណិជ្ជកម្មឯកជន។ ក្នុងខែកុម្ភៈ ឆ្នាំ២០១១ អ្នករាយការណ៍ពិសេស បានធ្វើទស្សនកិច្ចទៅកាន់ខេត្តកំពង់ឆ្នាំង ហើយបានឃើញផ្ទាល់ភ្នែក អំពីស្ថានភាពរស់នៅរបស់អ្នកភូមិដែលត្រូវបានគេបណ្តេញចេញពីដីធ្លីរបស់ខ្លួននៅដើមឆ្នាំ២០០៨ ដោយគ្មានសំណង ខណៈដែលករណីអ្នកភូមិឡពាងឃុំតាចេស ស្រុកកំពង់ត្រឡាច កំពុងរង់ចាំការសំរេចពីគណៈកម្មការសុរិយោដីស្រុកនិងបានបញ្ជូនទៅអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី(NALDR)។ បើទោះជាសហគមន៍បានប្តឹងទាមទារសិទ្ធិលើដីរបស់ខ្លួនក្តី ក៏ដីនោះត្រូវបានគេធ្វើការផ្ទេរប្រគល់ទៅឲ្យ KDC International ដែលជាក្រុមមួយដែលគ្រប់គ្រងដោយប្រពន្ធរបស់រដ្ឋមន្ត្រីមួយរូបនៃរដ្ឋាភិបាល។ អ្នកភូមិ ៨ នាក់ រាប់ទាំងប្រធានភូមិម្នាក់ និងបុគ្គលិកម្នាក់របស់អង្គការក្រៅ

រដ្ឋាភិបាលមួយ ដែលបានជួយដល់អ្នកភូមិដែលរងផលប៉ះពាល់ ត្រូវបានចោទប្រកាន់ពីបទបំពានលើទ្រព្យសម្បត្តិអ្នកដទៃ ការញុះញង់ និង ការផ្សព្វផ្សាយព័ត៌មានមិនពិត (ព័ត៌មានលំអិតខាងក្រោម ក្នុងផ្នែកសេរីភាពក្នុងការបញ្ចេញមតិ)។

១៤. ក្នុងខែមិថុនា ឆ្នាំ២០១១ អ្នករាយការណ៍ពិសេសបានជួបជាមួយប្រជាពលរដ្ឋបីគ្រួសារ ដែលត្រូវបានគេបង្ខំឲ្យចេញពីលំនៅដ្ឋានរបស់ខ្លួនក្នុងសង្កាត់ភ្នំពេញថ្មី ខណ្ឌឫស្សីកែវ (បច្ចុប្បន្ន ខណ្ឌសែនសុខ) ទោះជាទំនាស់ដីធ្លីមួយនេះមិនទាន់បានដោះស្រាយចប់សព្វគ្រប់ តាំងពីឆ្នាំ១៩៩២ មក។ គ្រួសារទាំងនោះ បានប្រាប់ឲ្យដឹងថា ពួកគាត់បានទិញដីនោះពីនាយទាហានម្នាក់ក្នុងឆ្នាំ១៩៩២ (គាត់មានឯកសារលក់ទិញត្រឹមត្រូវ ប៉ុន្តែការព្យាយាមសុំប័ណ្ណកម្មសិទ្ធិលើដីធ្លីនោះពីសាលារាជធានីភ្នំពេញ មិនបានសំរេច)។ ចាប់តាំងពីខែកញ្ញា ឆ្នាំ២០០៣ មក មានសេចក្តីរាយការណ៍ថា មានការប៉ុនប៉ងជាច្រើនលើកច្រើនសារ ដើម្បីដណ្តើមកាន់កាប់ដីនេះ និង បណ្តេញគ្រួសារប្រជាពលរដ្ឋទាំងនេះចេញពីទីតាំងនេះ ដែលមានការផ្តល់សំណងតិចតួច ឬ គ្មានទាល់តែសោះ ដែលពួកគាត់បានធ្វើការតវ៉ា។ ដំបូងរឿងក្តីនេះ ត្រូវបានសាលាដំបូងរាជធានីភ្នំពេញពិនិត្យ បន្ទាប់មកបានបញ្ជូនមកគណៈកម្មការសុរិយោដីក្រុងក្នុងឆ្នាំ២០០៤ ហើយនៅតែរង់ចាំ និងមិនអាចដោះស្រាយបានរយៈពេលជាច្រើនឆ្នាំ។

១៥. ក្នុងខែមិថុនា ឆ្នាំ២០១១ មានការប៉ះទង្គិចដោយហឹង្សាមួយបានកើតបានកើតឡើងរវាងអាជ្ញាធរខេត្តកំពង់ស្ពឺ និងអ្នកភូមិនៅស្រុកឧដុង្គពាក់ព័ន្ធនឹងទំនាស់ដីធ្លីមួយកន្លែងដែលមានទំហំ ៦៥ ហិកតា ដែលប្រជាពលរដ្ឋនៅតំបន់នោះកំពុងបង្កបង្កើនផលកសិកម្ម និងការបំផ្លិចបំផ្លាញបានធ្វើឡើងដោយចេតនាលើផ្ទះចំនួនបីខ្នងស្ថិតនៅលើដីដែលប្រជាពលរដ្ឋប្រាំគ្រួសារបានប្រើប្រាស់។ សមាជិកកងរាជអាវុធហត្ថចំនួនបួនរូប និងប្រជាពលរដ្ឋយ៉ាងតិចក៏ប្រាំមួយនាក់ដែរ ត្រូវបានគេរាយការណ៍ថា បានរងរបួសនៅក្នុងឧប្បត្តិហេតុនេះ។ ការប៉ះទង្គិចនេះបានកើតចេញពីទំនាស់ដីធ្លីរ៉ាំរ៉ៃមួយលើដីមួយកន្លែងដែលមានទំហំ ៦៥ ដែលប្រជាពលរដ្ឋចំនួន ៨៨ គ្រួសារអះអាងថា បានរស់នៅទីនោះតាំងពីដើមទសវត្សរ៍ឆ្នាំ១៩៨០ រហូតមក។ ទំនាស់នេះបានចាប់ផ្តើមកើតមានបន្ទាប់ពីនាយទាហានមួយចំនួន ត្រូវបានគេអះអាងថាបានលក់ដីនោះទៅឲ្យក្រុមហ៊ុនតៃវ៉ាន់មួយឈ្មោះក្រុមហ៊ុន ម៉េង គាត (គ្រប់គ្រងដោយអ្នកជំនួញតៃវ៉ាន់មួយរូប ដែលបានចូលសញ្ជាតិខ្មែរ) ដែលបច្ចុប្បន្ននេះអះអាងថា គាត់គឺជាម្ចាស់ដីនេះ អ្នកស្រុកបានបដិសេធការលក់ដីនោះ។ ទំនាស់នេះបានរង់ចាំការសំរេចសេចក្តីក្នុងប្រព័ន្ធតុលាការតាំងពីឆ្នាំ២០០៤ ហើយក្នុងខែធ្នូ ឆ្នាំ២០០៩ តុលាការកំពូលបានចេញសេចក្តីសំរេចប្រឆាំងការ

ទាមទាររបស់អ្នកស្រុក។ ការប៉ះទង្គិចនេះបានកើតមានបន្ទាប់ពីលោក គុជ សុភាង បានដឹកនាំកំលាំងប្រដាប់អាវុធមួយក្រុម ដែលមានសមាសភាពនគរបាល និងកងរាជអាវុធហត្ថ ចុះអនុវត្តសាលក្រមរបស់តុលាការកំពូល។

១៦. នេះជាករណីមួយចំនួន ដែលជាតួយ៉ាងនៃបញ្ហាពាក់ព័ន្ធនឹងសិទ្ធដីធ្លីនៅកម្ពុជា។ ទោះជាមានករណីមួយចំនួន ដែលរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន បានផ្តល់កញ្ចប់ថវិកាសមហេតុផលមួយដល់អ្នកភូមិនៅទីតាំងផ្សេងៗ ដើម្បីឲ្យពួកគាត់ទៅតាំងទីលំនៅថ្មីនៅកន្លែងផ្សេងទៀត ដោយសាររដ្ឋត្រូវការដីនោះប្រើប្រាស់សំរាប់ជាប្រយោជន៍សាធារណៈក្តី ក៏នៅមានករណីច្រើនលើសលុប ដែលរដ្ឋាភិបាលបានចាត់វិធានធ្ងន់ដៃលើអ្នកភូមិនៅក្នុងករណីទំនាស់ដីធ្លីដែរ។

១៧. នៅដើមឆ្នាំ២០១០ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី(CLP) បានចេញសេចក្តីព្រាងគោលនយោបាយមួយស្តីពីលំនៅដ្ឋាន ដែលទទួលស្គាល់សិទ្ធិមានលំនៅដ្ឋានសមរម្យ ប៉ុន្តែទោះជាដូច្នេះក្តី គោលនយោបាយនេះ នៅតែមិនទាន់សម្រេចនៅឡើយទេ។ ក្នុងខែឧសភា ឆ្នាំ២០១០ រដ្ឋាភិបាលបានអនុម័តសារាចរមួយស្តីពីការតាំងទីលំនៅបណ្តោះអាសន្ននៅតំបន់ទីប្រជុំជន ដែលផ្តល់ឲ្យមានដោះស្រាយករណីមួយស្តីពីការអភិវឌ្ឍន៍នៅនឹងកន្លែង និងការតាំងទីលំនៅថ្មី។ ទោះជាយ៉ាងក៏ដោយ ការដោះស្រាយនេះមិនបានអនុវត្តលក្ខណៈជាប្រព័ន្ធ ដែលកំណត់ច្បាស់លាស់ពីភាពស្របច្បាប់នៃតាំងទីលំនៅថ្មីនៅតំបន់ទីប្រជុំជនទេ។ អ្នករាយការណ៍ពិសេសសង្ឃឹមថា នឹងមានការផ្អាកជាបណ្តោះអាសន្នការបណ្តេញប្រជាពលរដ្ឋរស់នៅបណ្តោះអាសន្ន នឹងត្រូវបានគោរពរហូតដល់ពេលដែលរដ្ឋអាចបង្កើនសមត្ថភាពរបស់ខ្លួនថែមទៀត ក្នុងការដោះស្រាយទំនាស់ដីធ្លីស្របតាមអនុសាសន៍របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស ក្នុងសេចក្តីសំរេចចិត្តរបស់ខ្លួនលេខ ១២/២៥ ដែលបានស្នើយ៉ាងទទូចដល់រដ្ឋាភិបាលសុំឲ្យ "បង្កើនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ក្នុងការដោះស្រាយប្រកបដោយសមធម៌ និងឆាប់រហ័សនូវបញ្ហាកម្មសិទ្ធិដីធ្លីក្នុងលក្ខណៈបើកចំហរ និងត្រឹមត្រូវ ស្របតាមច្បាប់ភូមិបាលឆ្នាំ២០០១ ដោយពង្រឹងការអនុវត្តន៍ច្បាប់នេះ តាមរយៈការបង្កើតគោលនយោបាយជាតិនានា ដើម្បីស្រាយបំភ្លឺនីតិវិធីទាំងឡាយដែលពាក់ព័ន្ធ" ។ អ្នករាយការណ៍ពិសេស ស្នើយ៉ាងទទូចដល់រដ្ឋាភិបាលឲ្យបង្កើតកិច្ចខិតខំប្រឹងប្រែងទ្វេដង ក្នុងការប្រើប្រាស់ទាំងក្របខ័ណ្ឌច្បាប់ដែលមានស្រាប់ ទាំងក្របខ័ណ្ឌច្បាប់ទាំងឡាយដែលនឹងបង្កើតឲ្យមាន ដើម្បីដោះស្រាយទំនាស់ ជាជាងការបណ្តោយឲ្យទំនាស់ដីធ្លីផ្ទុះចេញជាអំពើហឹង្សា ដូចដែលបានឃើញក្នុងរូបភាពខ្លាំងខ្លានៅក្នុងពេលកំពុងធ្វើរបាយការណ៍នេះ។

## ខ. សេរីភាពខាងការបញ្ចេញមតិ

១៨. ស្ថានភាពសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនិងយោបល់ នៅកម្ពុជានៅតែជាកង្វល់នៅឡើយ។ កន្លងមក រដ្ឋាភិបាលបានប្រើប្រាស់មិនសមាមាត្រនូវបញ្ញត្តិច្បាប់ស្តីពីការបរិហារកេរ្តិ៍ និង ការផ្សាយព័ត៌មានមិនពិត លើអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស និងមេដឹកនាំគណបក្សនយោបាយនានា ដែលប្រហែលមកពីហេតុនេះហើយ ទើបពួកគាត់ធ្វើការរិតត្បិតការបញ្ចេញមតិខ្លួនឯង ដោយមានការភ័យខ្លាចត្រូវគេចោទប្រកាន់ខ្លួនពីបទល្មើសដូចនេះ។

១៩. អ្នករាយការណ៍ពិសេសបានកត់សំគាល់ថា បញ្ញត្តិមួយចំនួន ក្នុងច្បាប់ជាច្រើននៅកម្ពុជា សូម្បីតែបញ្ញត្តិខ្លះក្នុងក្រមព្រហ្មទណ្ឌថ្មី ក៏ចែងលើសពីការកំណត់ក្នុងបទដ្ឋានអន្តរជាតិដែរ ក្នុងការកំរិតសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ និងក្នុងការអនុវត្តន៍ ក៏ដូចជា ក្នុងការបកស្រាយច្បាប់ដូចនេះ។ តុលាការនានា មិនបង្ហាញពីការយល់ដឹងគ្រប់គ្រាន់អំពីយុត្តិសាស្ត្រនិងការអនុវត្តន៍ជាអន្តរជាតិដែលកំពុងវិវត្តន៍ និងមាននិន្នាការទៅរកការបកស្រាយច្បាប់តាមន័យនៃពាក្យច្បាប់ ច្រើនជាងការបកស្រាយតាមច្បាប់ស្មារតីច្បាប់។ ជាអាទិ៍ ក្នុងខែសីហា ឆ្នាំ២០១០ បុគ្គលិកមួយរូបធ្វើការនៅអង្គការសិទ្ធិមនុស្សកម្ពុជាមួយ (អង្គការលីកាដូ) លោក លាង សុខជួន និង បុគ្គលពីរនាក់ទៀត ឈ្មោះ លោក ថាច់ វណ្ណៈ និងលោក ថាច់ លី ត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគាររយៈពេលពីរឆ្នាំ និងពិន័យជាប្រាក់ពីរលានរៀន ហើយចុងចោទម្នាក់ទៀត គឺលោក ថាច់ យុង ហ្សុង ត្រូវបានតុលាការបើកសវនាការកំបាំងមុខ និងផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេលបីឆ្នាំ។ ជនទាំងនេះ ត្រូវជាប់ចោទពីបទចែកខិត្តប័ណ្ណប្រឆាំងនឹងរដ្ឋាភិបាល នៅខេត្តតាកែវ កាលពីថ្ងៃទី៤ ខែមករា ឆ្នាំ២០១០។ សវនាការកាត់សេចក្តី នៅថ្ងៃទី៣០ ខែសីហា ត្រូវបានគេសំគាល់ឃើញមានចំណុចឆកល្វែងជាច្រើន បង្ហាញថា ចុងចោទទាំងនោះមិនបានទទួលការកាត់សេចក្តីមួយត្រឹមត្រូវឡើយ។ ភស្តុតាងដែលបានលើកបង្ហាញ និងកាលៈទេសៈជុំវិញករណីនេះ បានបញ្ជាក់ថា ធាតុផ្សំនៃបទល្មើសដែលកំណត់ក្នុងមាត្រា៦២ នៃក្រមព្រហ្មណ្ឌអំពីការផ្សាយព័ត៌មានមិនពិតនោះ គឺមិនសមស្របនោះទេ ដោយសារការអះអាងពីការចែកខិត្តប័ណ្ណនេះថាធ្វើឲ្យអន្តរាយដល់សន្តិភាព និងសណ្តាប់ធ្នាប់សាធារណៈ ប៉ុន្តែបន្ទាប់ពីការរកឃើញខិត្តប័ណ្ណនេះ គេមិនឃើញមានហេតុការណ៍ណាមួយបានកើតឡើងដូចដែលបានអះអាងនោះឡើយ។

២០. អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា អ្នករាយការណ៍ពិសេសស្តីពីការលើកស្ទួយនិងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនិងយោបល់ អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពនៃអ្នកការពារសិទ្ធិមនុស្ស និងអ្នករាយការណ៍ពិសេសស្តីពីឯករាជ្យចៅក្រមនិងមេធាវី បានរួមគ្នាបញ្ជូនសេចក្តីអំពាវនាវបន្ទាន់មួយទៅរដ្ឋាភិបាលកម្ពុជានៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១០ អំពីករណីនេះ។ អ្នករាយការណ៍ពិសេសទាំងនេះ បានសំដែងកង្វល់ថា ស្ថានភាពបុគ្គលបួននាក់នេះ អាចឈានទៅដល់ការរំលោភសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិទទួលបានការកាត់សេចក្តីប្រកបដោយភាពត្រឹមត្រូវនិងយុត្តិធម៌។ ពួកគាត់បានសំដែងកង្វល់ផងដែរថា ការកាត់ទោសបុរសម្នាក់ (ក្នុងចំណោមបុរសបួននាក់នោះ) ដែលជាអ្នកការពារសិទ្ធិមនុស្សមួយរូប ផ្អែកលើភស្តុតាងគួរឲ្យសង្ស័យ អាចជះផលអាក្រក់លើបរិកាសការងាររបស់អ្នកការពារសិទ្ធិមនុស្សនៅកម្ពុជា។ អ្នករាយការណ៍ពិសេសទាំងនេះ បានស្នើសុំឲ្យមានការស្រាយបំភ្លឺអំពីដំណើរការស៊ើបអង្កេត និងការសាកសួរតាមផ្លូវច្បាប់ និងការសាកសួរដទៃផ្សេងទៀត ដែលពាក់ព័ន្ធនឹងករណីទាំងនេះ អំពីវិធានការទាំងឡាយដែលបានចាត់ ដើម្បីធានាឲ្យការកាត់សេចក្តីប្រកបដោយភាពត្រឹមត្រូវនិងយុត្តិធម៌ និង អំពីវិធីឬរបៀបដាក់ទោសទណ្ឌដល់ចុងចោទ លើករណីចោទប្រកាន់ពីការចែកខិត្តប័ណ្ណ ដែលជាដើមចមនៃការរិតត្បិតលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ ក្នុងពេលកំពុងធ្វើរបាយការណ៍នេះ មិនទាន់បានទទួលការឆ្លើយតបណាមួយពីរដ្ឋាភិបាលនៅឡើយទេ។

២១. ករណីស្រដៀងគ្នានេះដែរ នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១១ អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា អ្នករាយការណ៍ពិសេសស្តីពីការលើកស្ទួយនិងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនិងយោបល់ អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពនៃអ្នកការពារសិទ្ធិមនុស្ស បានរួមគ្នាបញ្ជូនលិខិតមួយច្បាប់ទៅរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្នើសុំឲ្យមានការស្រាយបំភ្លឺអំពីមូលដ្ឋានច្បាប់លើករណីរបស់លោក សម ចាន់គា និង លោក រាជ សីម៉ា ត្រូវបានតុលាការកាត់ទោសពីបទការផ្សាយព័ត៌មានមិនពិត និងការបរិហារកេរ្តិ៍ តាមមាត្រា៣០៥ នៃក្រមព្រហ្មទណ្ឌថ្មី តាមការលើកឡើងក្នុងបទសម្ភាសន៍នៃវិទ្យុមួយ ស្ថានភាពផ្លូវច្បាប់មិនទាន់ច្បាស់លាស់អំពីទំនាស់ដីធ្លីដែលកំពុងបន្ត និងទង្វើខុសច្បាប់របស់ក្រុមហ៊ុនសាមី (ក្រុមហ៊ុន KDC International) ដែលបានដឹកជញ្ជូនម៉ាស៊ីនមកឈូសឆាយលើដីនោះ (សូមមើលដើមរឿងព័ត៌មាននៅផ្នែកស្តីពីសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន)។ លោក ចាន់គា ជាអ្នកសម្របសម្រួលមូលដ្ឋានមួយរូបនៃអង្គការសិទ្ធិមនុស្សមួយ (អង្គការអាដហុក)។ គាត់បានធ្វើការស្រាយបំភ្លឺមួយតាមវិទ្យុអាស៊ីសេរីថា "អ្វីដែលក្រុមហ៊ុននេះបានធ្វើ គឺជាការរំលោភបំពាន

ពីព្រោះតុលាការមិនទាន់សំរេចយ៉ាងណានៅឡើយទេចំពោះករណីនេះ។ ដូច្នេះហើយ ក្រុមហ៊ុនគួរតែបញ្ឈប់សកម្មភាពរបស់ខ្លួនសិន រង់ចាំរហូតដល់មានការសំរេចណាមួយពីតុលាការជាមុនសិន។″ ក្រុមហ៊ុនបានអះអាងថា ការស្រាយបំភ្លឺនេះគឺមិនពិតនោះទេ ហើយពេលទទួលពាក្យបណ្ដឹងនោះភ្លាម ព្រះរាជអាជ្ញាបានធ្វើការចោទប្រកាន់នៅអ្នកសម្របសម្រួលអង្គការអាហុករូបនេះពីបរិហារកេរ្តិ៍។ នៅពេលដែលករណីនេះបានដល់ដៃតុលាការ ការកាត់សេចក្ដីមានចំណុចឆកល្វែងជាច្រើន ដែលសឲ្យឃើញថា សវនាការនេះមិនបំពេញតាមបទដ្ឋានស្ដីពីការជំនុំជម្រះក្ដីប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ឡើយ។ លោក ចាន់គា ត្រូវបានតុលាការ សំរេចឲ្យផ្ដល់សំណងនិងបង់ប្រាក់ពិន័យ ៤ លានរៀល ពុំនោះទេ ត្រូវប្រឈមនឹងទោសជាប់ពន្ធនាគាររយៈពេលបីខែ។ លោក សីម៉ា ត្រូវបានតុលាការសំរេចឲ្យផ្ដល់សំណងនិងបង់ប្រាក់ពិន័យ ១០ លានរៀល ពុំនោះទេ ត្រូវប្រឈមនឹងទោសជាប់ពន្ធនាគាររយៈពេលប្រាំមួយខែ។ ការប្រើចំណាត់ការបណ្ដឹងបរិហារកេរ្តិ៍ជាបទព្រហ្មទណ្ឌប្រឆាំងនឹងសកម្មជនការពារសិទ្ធិមនុស្ស ដើម្បីជំរុញឲ្យមានដំណោះស្រាយមួយសមស្របលើទំនាស់ដីធ្លីនោះ គឺជាបញ្ហាមួយនៃកង្វល់ធ្ងន់ធ្ងរ។ ក្នុងពេលកំពុងធ្វើរបាយការណ៍នេះ មិនទាន់បានទទួលការឆ្លើយតបណាមួយពីរដ្ឋាភិបាលនៅឡើយទេ។

២២. ករណីស្រដៀងគ្នានេះមួយទៀត គឺករណីលោក សេង គុណការ ជាបុគ្គលិកមួយរូបនៃអង្គការស្បៀងអាហារពិភពលោក(WFP) ដែលត្រូវបានសាលាដំបូងរាជធានីភ្នំពេញកាត់ទោសពីបទញុះញង់ឲ្យមានការប្រព្រឹត្តបទឧក្រិដ្ឋនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១០ ហើយត្រូវបានផ្ដន្ទាទោសដាក់ពន្ធនាគាររយៈពេលប្រាំមួខែ និងពិន័យជាប្រាក់ ១ លានរៀល។ នៅថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១០ លោក គុណការ ត្រូវបានចាប់ខ្លួន និងបានឃុំខ្លួននៅសាលាខណ្ឌឫស្សីកែវ ដើម្បីធ្វើការសាកសួររយៈពេល ៤៨ ម៉ោង។ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១០ គាត់ត្រូវបានវិនិច្ឆ័យទោសដោយសាលាដំបូងរាជធានីភ្នំពេញ តាមក្រមព្រហ្មទណ្ឌថ្មី និងត្រូវបានផ្ដន្ទាទោសពីបទបោះពុម្ពអត្ថបទព័ត៌មានពីគេហទំព័រអ៊ិនធឺណែតវិបសាយ ហើយចែកចាយអត្ថបទនោះទៅសហការីពីរនាក់នៅកន្លែងធ្វើរបស់គាត់។ អត្ថបទនោះមានរូបថ្លុកគ្រាប់ចំអករិះគន់មេដឹកនាំគណបក្សនយោបាយមួយចំនួន ដែលគេហៅថា "ជនក្បត់ជាតិ″។ អ្នកសង្កេតការណ៍មិនត្រូវបានគេអនុញ្ញាតឲ្យចូលស្ដាប់សវនាការនេះទេ ដែលជាសវនាការមួយបិទទ្វារ។ សវនាការនេះបានធ្វើពីរថ្ងៃ បន្ទាប់ពីការចាប់ខ្លួន ហើយនៅថ្ងៃអាទិត្យ ដែលតាមធម្មតាថ្ងៃនេះតុលាការបិទទ្វារ(មិនធ្វើការទេ) លើកលែងតែករណីពិសេសមួយចំនួនប៉ុណ្ណោះ។ វាទំនងជាព្រះរាជអាជ្ញាមិនមានពេលគ្រប់គ្រាន់ដើម្បីបើកការស៊ើបសួរករណីនេះ ហើយតុលាការមានការប្រញាប់ប្រញាល់ចេញសាលក្រមដោយ

ទុកពេលសំរាប់ការជំនុំជម្រះក្តីមួយត្រឹមត្រូវឡើយ។ សេចក្តីអំពាវនាវជាបន្ទាន់មួយត្រូវបានរួមគ្នាបញ្ជូនដោយអ្នករាយការណ៍ពិសេស ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា អ្នករាយការណ៍ពិសេសស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនិងយោបល់ និងប្រធានអ្នករាយការណ៍នៃក្រុមការងារស្តីពីការឃុំខ្លួនតាមទំនើងចិត្ត នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១១ ដើម្បីស្វែងរកការឆ្លើយបំភ្លឺអំពីមូលដ្ឋានច្បាប់នៃការកាត់ទោសលោក គុណកា។ អ្នករាយការណ៍ពិសេសទាំងនេះ បានសំដែងកង្វល់ថា មាត្រា ៤៩៥ នៃក្រមព្រហ្មទណ្ឌថ្មី អាចត្រូវបានគេធ្វើការបកស្រាយ ក្នុងគោលដៅរិតត្បិតការប្រើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ យោបល់ និងព័ត៌មាន ច្រើនជាង ក្នុងគោលដៅទប់ស្កាត់សាធារណៈជនមិនឲ្យប្រព្រឹត្តបទល្មើសណាមួយ។ ក្នុងពេលកំពុងធ្វើរបាយការណ៍នេះ មិនទាន់បានទទួលការឆ្លើយតបណាមួយពីរដ្ឋាភិបាលនៅឡើយទេ។

២៣. អ្នករាយការណ៍ពិសេសបានសង្កេតឃើញថា តុលាការនានាអនុវត្តច្បាប់មិនស្របតាមចរិតលក្ខណៈនិងវិសាលភាពនៃគោលការណ៍នីតិរដ្ឋតាំងតែពីដើមទីមក ហើយហានិភ័យនេះ កំពុងត្រូវបានស្ថាប័ននីតិប្រតិបត្តិប្រើប្រាស់សំរាប់គោលដៅនយោបាយ។ ឧទាហរណ៍មួយនៃករណីនេះ គឺការកាត់ទោសកំបាំងមុខ លោក សម រង្ស៊ី ប្រធានគណបក្សឲ្យជាប់ពន្ធនាគាររយៈពេលដប់ឆ្នាំ បន្ទាប់ពីគាត់ត្រូវបានគេរកឃើញថាមានពិរុទ្ធភាពក្នុងរឿងនយោបាយពីបទចោទក្លែងឯកសារសាធារណៈ និងការផ្សាយព័ត៌មានមិនពិត។ អ្នករាយការណ៍ពិសេសបានមានសង្ឃឹមថាសាលាឧទ្ធរណ៍ ឬតុលាការកំពូលនឹងមានភាពមិនលំអៀងច្រើនជាងនេះ ក្នុងការដោះស្រាយបណ្តឹងឧទ្ធរណ៍របស់គាត់។ ប៉ុន្តែប្រការដែលគួរឲ្យសោកស្តាយនោះគឺ តុលាការកំពូលបានសំរេចក្នុងខែមីនា ឆ្នាំ២០១១ តំកល់សាលដីកាសាលាឧទ្ធរណ៍ ដែលតុលាការនេះ(សាលាឧទ្ធរណ៍) បានដំកល់សាលក្រមសាលាដំបូងហើយដែរ។ រដ្ឋាភិបាលបានធ្វើការចោទប្រកាន់លោក សម រង្ស៊ី ថាបានបំភ្លៃផែនទីមួយដែលបង្ហាញថាប្រទេសវៀតណាមបានទន្ទ្រានលើទឹកដីកម្ពុជា។ នៅក្នុងប្រទេសមួយដែលលិទ្ធិប្រជាធិបតេយ្យដំណើរល្អ បញ្ហានយោបាយដូចនេះនឹងត្រូវបានគេលើកយកមកជជែកពិភាក្សាគ្នានៅក្នុងសភា ហើយបានក្លាយប្រធានបទមួយនៃការជជែកដេញដោលជាសាធារណៈ ច្រើនជាងការដាក់បញ្ហានេះជាកម្មវត្ថុនៃករណីបណ្តឹងព្រហ្មទណ្ឌនៅចំពោះមុខតុលាការ។ ការពិនិត្យពិច័យលើសកម្មភាពការងាររបស់រដ្ឋាភិបាល និងការតម្រូវឲ្យរដ្ឋាភិបាលធ្វើការឆ្លើយតបចំពោះមតិរិះគន់ទាំងឡាយណា ដែលកើតចេញពីការសំរេចគោលនយោបាយរបស់ខ្លួននោះ គឺជាមុខនាទីរបស់មួយក្នុងចំណោមមុខនាទីជាមូលដ្ឋានរបស់មេដឹកនាំគណបក្សប្រឆាំងទាំងឡាយ ហើយពួកគេ

មិនត្រូវជាកម្មវត្ថុនៃចំណាត់ការផ្ទែកព្រហ្មទណ្ឌចំពោះការអនុវត្តន៍ការទទួលខុសត្រូវរបស់ខ្លួនដោយសន្តិវិធីឡើយ។

២៤. នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ អ្នករាយការណ៍ពិសេសបានសរសេរលិខិតមួយទៅលោក នាយករដ្ឋមន្ត្រី និងបានផ្តល់គាត់នូវកំណត់សង្ខេបមួយ គូសបញ្ជាក់អំពីទស្សនវិស័យខាងសិទ្ធិមនុស្សអន្តរជាតិស្តីពីការប្រើប្រាស់ចំណាត់ការបណ្តឹងបរិហារកេរ្តិ៍ និងការចោទប្រកាន់ពីការផ្សាយព័ត៌មានមិនពិត។ អ្នករាយការណ៍ពិសេសបានគូសបញ្ជាក់អំពីសារសំខាន់នៃការការពារលំហរប្រជាធិបតេយ្យ សំរាប់ការជជែកពិភាក្សាដេញដោលជាសាធារណៈថា អាជ្ញាធរសាធារណៈ អ្នកនយោបាយ ព្រមទាំងសមាជិកសារព័ត៌មាន និងសាធារណៈជនទាំងឡាយដែលចូលរួមក្នុងការជជែកដេញដោលទាំងអស់ត្រូវចេះអត់ឱនឲ្យគ្នាចំពោះមតិខ្វែងគំនិត និងមិនត្រូវចាត់ទុកមតិយោបល់នោះថាជាការវាយប្រហារជាបុគ្គលឡើយ។ អ្នករាយការណ៍ពិសេសបាននិយាយសំដៅដល់និន្នាការគួរឲ្យព្រួយបារម្ភមួយនៃការរឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិក្នុងរូបភាពបណ្តឹងបរិហារកេរ្តិ៍ជាបទព្រហ្មទ័ណ្ឌ ការផ្សាយព័ត៌មានមិនពិត និងការញុះញង់ដែលបានបណ្តាលឲ្យបុគ្គលមួយចំនួនត្រូវជាប់ពន្ធនាគារ រាប់ទាំងអ្នកសារព័ត៌មាន បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងសមាជិកសភាមួយចំនួន ដែលពួកគាត់គ្មានចេតនាធ្វើឲ្យប៉ះពាល់ដល់សន្តិសុខជាតិឡើយ។ ក្នុងករណីបរិហារកេរ្តិ៍ អ្នករាយការណ៍ពិសេស បានកត់សំគាល់ជាប្រចាំថា ដើមបណ្តឹងទំនងជាមិនមានភស្តុតាងបង្ហាញថា កិត្តិស័ព្ទឬកេរ្តិ៍ឈ្មោះរបស់ខ្លួនត្រូវបានគេធ្វើឲ្យខូច(នេះជាធាតុផ្សំមួយនៃបទបរិហារកេរ្តិ៍)។ ក្នុងករណីផ្សាយព័ត៌មានមិនពិត អ្នករាយការណ៍ពិសេស បានកត់សំគាល់ថា មិនមានតឹកតាងណាមួយត្រូវបានគេលើកបង្ហាញតុលាការថា ព័ត៌មាននោះបង្កអន្តរាយដល់សន្តិសុខជាតិឡើយ (នេះជាធាតុផ្សំមួយនៃបទផ្សាយព័ត៌មានមិនពិត)។

## *គ. សេចក្តីព្រាងច្បាប់ស្តីពីសមាគម និង អង្គការមិនមែនរដ្ឋាភិបាល*

២៥. ក្នុងខែកញ្ញា ឆ្នាំ២០០៨ រាជរដ្ឋាភិបាល បានសំរេចអនុម័តច្បាប់មួយ គ្រប់គ្រងសកម្មភាពសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងនីតិកាលទីបួននៃរដ្ឋសភា (២០០៨-២០១២)។ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០ ក្រសួងមហាផ្ទៃបានចេញផ្សាយជាសាធារណៈនូវសេចក្តីព្រាងច្បាប់ដំបូង និងបានអញ្ជើញអង្គការមិនមែនរដ្ឋាភិបាលនានា និងអ្នកដែលពាក់ព័ន្ធឯទៀត ចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី

មួយ អំពីសេចក្តីព្រាងច្បាប់នេះនៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១១។ តួនាទីរបស់អង្គការសង្គមស៊ីវិលក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងនយោបាយរបស់កម្ពុជា ត្រូវបានទទួលស្គាល់ដោយលោកនាយករដ្ឋមន្ត្រី ក្នុងសន្ទរកថារបស់លោកនៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៩ និងថ្ងៃទី៦ មិថុនា ឆ្នាំ២០១១ និងមន្ត្រីរដ្ឋាភិបាលជាន់ខ្ពស់ជាច្រើនទៀត។ អង្គការសង្គមស៊ីវិលភាគច្រើន បានដើរតួនាទីមួយបំពេញបន្ថែមលើតួនាទីរបស់រដ្ឋ ក្នុងការជួយ ឬការផ្តល់សេវាសង្គមសំខាន់ៗក្នុងវិស័យអប់រំ សុខភាព ការអភិវឌ្ឍន៍ជនបទ អនាម័យ សុខមាលភាពសង្គម និង ក្នុងកិច្ចការពារធនធានធម្មជាតិ និង បរិស្ថាន។

២៦. ដោយឃើញពីសារសំខាន់នៃការបង្កើតសង្គមស៊ីវិល សំរាប់ការអភិវឌ្ឍន៍ប្រទេស ការសំរេចអនុម័តច្បាប់មួយដើម្បីគ្រប់គ្រងសកម្មភាពសមាគម និងអង្គការមិនមែនរដ្ឋាភិបាលគឺជាគំនិតផ្តួចផ្តើមមួយដ៏សំខាន់ ដែលតម្រូវឲ្យមានការយកចិត្តទុកដាក់ហ្មត់ចត់ ដោយឃើញពីទំនាក់ទំនងការងាររបស់ខ្លួនរយៈពេលវែង សំរាប់ការអភិវឌ្ឍន៍សង្គមកម្ពុជាផ្ទាល់។ ក្នុងពេលពីរឆ្នាំកន្លងមក អង្គការសិទ្ធិមនុស្ស និងអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត កំពុងធ្វើការលើកស្ទួយ និងការពារសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋានរបស់ប្រជាពលរដ្ឋក្រីក្របំផុត ការអភិវឌ្ឍន៍ប្រកបដោយចិរភាព ឬសិទ្ធិធានាការពារដោយរដ្ឋធម្មនុញ្ញជាអាទិ៍ សេរីភាពក្នុងការបញ្ចេញមតិ សិទ្ធិជួបប្រជុំ និងសេរីភាពខាងសារព័ត៌មាន កំពុងទទួលរងកាន់តែខ្លាំងឡើងនូវរូបភាពផ្សេងៗនៃការយាយីរំខាន និងការបំភិតបំភ័យរាប់ទាំង ការរិតត្បិតលើការដើរហើរ និងសេរីភាពក្នុងការប្រជុំ ការគំរាមជាពាក្យសំដី ការគំរាមចាត់ វិធានការតាមផ្លូវច្បាប់ ហើយក្នុងករណីខ្លះ មានការចាត់វិធានការជាបណ្តឹងព្រហ្មទណ្ឌទៀតផង។ កិច្ចខិតខំប្រឹងប្រែងរបស់ពួកគាត់ ដើម្បីអប់រំ និង ណែនាំសហគមន៍មូលដ្ឋាន អំពីសិទ្ធិស្របច្បាប់របស់គាត់ និងអំពីរបៀបប្រើប្រាស់សិទ្ធិទាំងនោះដោយសន្តិវិធី តាមរយៈស្ថានប័នដែលមានស្រាប់ កំពុងទទួលរងកាន់តែខ្លាំងឡើងនូវការចោទប្រកាន់ថាជា "ការញុះញង់" និងមានជាប់ជំពាក់ជាមួយគណៈបក្សប្រឆាំង។

២៧. អ្នករាយការណ៍ពិសេសមានការពេញចិត្តផងដែរ ចំពោះកិច្ចប្រជុំដែលក្រសួងពាក់ព័ន្ធនានាបានរៀបចំធ្វើឡើង ដើម្បីពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ជាមួយភាគីពាក់ព័ន្ធទាំងឡាយ ហើយសង្ឃឹមថាការអនុវត្តន៍ល្អនេះ នឹងបន្តធ្វើតទៅទៀតនៅក្នុងវិស័យដទៃទៀត។ ទោះជាដូច្នេះក្តី ដើម្បីឲ្យកិច្ចពិគ្រោះយោបល់នេះ ប្រព្រឹត្តទៅប្រកបដោយអត្ថន័យ សេចក្តីព្រាងច្បាប់ចុងក្រោយបំផុត គួរតែដាក់បញ្ចូលរាល់សំណើរឬអនុសាសន៍សមស្របទាំងឡាយ ដែលបានធ្វើនៅក្នុងអំឡុងពេលនៃកិច្ចប្រជុំពិគ្រោះយោបល់នោះ ដើម្បីឲ្យនៅពេលដែលសភា

អនុម័តហើយ ច្បាប់នេះអាចឲ្យសមាគម ឬអង្គការពាក់ព័ន្ធនានា អាចពង្រឹងសកម្មភាពការងាររបស់ខ្លួន ច្រើនជាង ការរិតត្បិតសកម្មភាពរបស់ពួកគេ។

២៨. នៅពេលកំពុងសរសេររបាយការណ៍នេះ មានទិដ្ឋភាពមួយចំនួនក្នុងសេចក្តីព្រាងច្បាប់ថ្មីនេះ នៅតែត្រូវការការយកចិត្តទុកដាក់ហ្មត់ចត់ ហើយគួរតែរៀបចំឲ្យមានការពិគ្រោះយោបល់មួយទូលំទូលាយជាងនេះ ដើម្បីស្រាយបញ្ហាកង្វល់ទាំងឡាយដែលអង្គការមិនមែនរដ្ឋាភិបាលខ្លួនឯងផ្ទាល់បានលើកឡើង។ នៅក្នុងលិខិតសុំការបំភ្លឺមួយដែលរួមគ្នាបញ្ជូន នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០១១ ដោយអ្នករាយការណ៍ពិសេសស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា អ្នករាយការណ៍ពិសេសស្តីពីស្ថានភាពនៃអ្នកការពារសិទ្ធិមនុស្ស អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពនៃការប្រជុំដោយសន្តិវិធី និងការបង្កើតសមាគម បង្ហាញកង្វល់អំពីបញ្ញត្តិមួយចំនួននៅក្នុងសេចក្តីព្រាងច្បាប់លើកទីពីរស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (សេចក្តីព្រាងច្បាប់ NGO) នៃព្រះរាជាណាចក្រកម្ពុជា អាចរារាំងរំខានដល់ការងារស្របច្បាប់របស់អង្គការ NGOs ក្នុងការលើកស្ទួយសិទ្ធិមនុស្ស។ អ្នករាយការណ៍ពិសេសបានបង្ហាញថា ដំណើរការចុះបញ្ជីគួរតែធ្វើឲ្យបានឆាប់រហ័ស ងាយទទួលបាន និង មានតម្លៃសមរម្យ ហើយស្ថាប័នទទួលបន្ទុកការចុះបញ្ជី គួរតែឯករាជ្យពីរដ្ឋាភិបាល។ អាស្រ័យហេតុនេះ រដ្ឋាភិបាលគួរបង្កើតនីតិវិធី និងកំណត់ រយៈពេលពិនិត្យពាក្យសុំឲ្យបានច្បាស់លាស់។ រដ្ឋាភិបាលគួរតែធានាការពារសិទ្ធិរបស់សមាគម ក្នុងការប្តឹងតវ៉ាប្រឆាំងនឹងការបដិសេធការចុះបញ្ជី ហើយថា គេគួរតែមានសិទ្ធិធ្វើបណ្តឹងសើរើប្រឆាំងនឹងការបដិសេធមិនទទួលពាក្យ និងមានការពិនិត្យឡើងវិញ ដោយតុលាការឯករាជ្យ ពាក់ព័ន្ធនឹងការសំរេចរបស់អាជ្ញាធរទទួលបន្ទុកការចុះបញ្ជី។ រដ្ឋាភិបាលមិនគួរដាក់ជាទោសព្រហ្មទណ្ឌ ឬដាក់ទោសព្រហ្មទណ្ឌចំពោះសកម្មភាពការងារទាំងឡាយធ្វើឡើង ដើម្បីការពារសិទ្ធិមនុស្ស និងដើម្បីចូលរួមក្នុងអង្គការទាំងឡាយដែលមិនបានចុះបញ្ជីឡើយ។

២៩. កិច្ចសន្ទនាមួយដែលបើកចំហរ ប្រកបដោយន័យស្ថាបនា និងមានការគោរពគ្នាទៅវិញទៅមក គឺជាការចាំបាច់ក្នុងការរួមគ្នាបង្កើតច្បាប់ NGOs មួយ ដែលមានគោលដៅពង្រឹងថែមទៀតដល់ការបង្កើតសង្គមស៊ីវិលនៅកម្ពុជា។ ទន្ទឹមនឹងកិច្ចសហប្រតិបត្តិការមានការរីកចំរើនហើយក្តី ក៏នៅមានបញ្ហាប្រឈមជាច្រើន ដែលក្នុងនោះបញ្ហាខ្លះអាចនឹងត្រូវបានដោះស្រាយបាន តាមរយៈការបង្កើនទំនាក់ទំនង និងកិច្ចពិភាក្សា។

៣០. នៅក្នុងលិខិតរបស់លោក ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ ផ្ញើជូនលោកនាយករដ្ឋមន្ត្រី អ្នករាយការណ៍ពិសេសបានរំលឹកឡើងវិញ អំពីការឆ្លើយតបជាវិជ្ជមានរបស់លោកនាយករដ្ឋមន្ត្រី ចំពោះសំណើរដែលលោកបានស្នើឲ្យមានការបង្កើតយន្តការមួយសំរាប់កិច្ចសហប្រតិបត្តិការប្រកបដោយអត្ថន័យនិងក្នុងន័យស្ថាបនា រវាងរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល នៅក្នុងជំនួបប្រជុំមួយក្នុងខែមករា ឆ្នាំ២០១០ ហើយបានគូសបញ្ជាក់ពីសេចក្តីត្រូវការឲ្យមានការរួមគ្នាបង្កើតយន្តការនេះ។ តាមស្មារតីនេះ លោកតំណាងពិសេសបានបញ្ជូនពង្រាងនៃសំណើរការងារមួយ ដែលបានសហការរៀបចំដោយអង្គការសិទ្ធិមនុស្សចំនួនប្រមាណជា ៣០០ អង្គការនៅកម្ពុជា ដាក់ស្នើទៅលោកនាយករដ្ឋមន្ត្រី ដើម្បីពិនិត្យពិចារណា។

៣១. ក្នុងការឆ្លើយតប អ្នករាយការណ៍ពិសេសមានក្តីសោមនស្សរីករាយ ដែលទទួលបានការបញ្ជាក់ច្បាស់ពីលោកនាយករដ្ឋមន្ត្រីថា លោកបានប្រគល់ភារកិច្ចនេះឲ្យមន្ត្រីពាក់ព័ន្ធ ដើម្បីសិក្សាលំអិតអំពីចំណុចដែលបានលើកបង្ហាញក្នុងខែកញ្ញា ឆ្នាំ២០១០។ នៅក្នុងលិខិតរបស់លោក លោកនាយករដ្ឋមន្ត្រីបានសំដែងក្តីសង្ឃឹមផងដែរថា នៅពេលដ៏ឆាប់នេះ សហការីរបស់លោក និងអ្នករាយការណ៍ពិសេសនឹងផ្តើមបើកកិច្ចពិភាក្សាមួយចំនួនប្រកបដោយន័យស្ថាបនា ដើម្បីស្រាយបញ្ហាដែលជាកង្វល់។ ក្នុងពេលជំនួបប្រជុំក្នុងខែកុម្ភៈ ឆ្នាំ២០១១ លោកនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់អំពីសេចក្តីត្រូវការឲ្យមានការចូលរួមពីសំណាក់អង្គការមិនមែនរដ្ឋាភិបាលច្រើនថែមទៀត ក្នុងយន្តការនេះ ដើម្បីបញ្ចូលនិងតំណាងឲ្យសង្គមស៊ីវិលពិតប្រាកដ។ អ្នករាយការណ៍ពិសេស លើកទឹកចិត្តដល់រដ្ឋាភិបាល និងសង្គមស៊ីវិល សូមបន្តកិច្ចសន្ទនាក្នុងគោលដៅឈានទៅបង្កើតយន្តការមួយសំរាប់កិច្ចពិគ្រោះយោបល់ជាទៀងទាត់។

## ឃ. *សេចក្តីព្រាងច្បាប់ស្តីពីសហជីពកម្មករ*

៣២. បច្ចុប្បន្ននេះ ក្រសួងការងារបាននិងកំពុងធ្វើសេចក្តីព្រាងច្បាប់ស្តីពីសហជីពកម្មករ និងកំពុងពិនិត្យអំពីភាពស្របគ្នានៃច្បាប់នេះជាមួយបទដ្ឋានអន្តរជាតិស្តីពីការងារ និងសិទ្ធិមនុស្ស។ ទោះជាដូច្នេះក្តី អ្នករាយការណ៍ពិសេស មានកង្វល់អំពីការកំរិតលើសេរីភាពក្នុងការបញ្ចេញមតិ និងការប្រជុំរបស់សមាជិកសហជីពកម្មករ។ នៅក្នុងអំឡុងពេលសរសេររបាយការណ៍នេះ ប្រធានសហជីពកម្មករមួយចំនួនបានប្រឈមនឹងការសងសឹក ជាអាទិ៍ ការគំរាមកំហែង ការចោទប្រកាន់ពីបទញុះញង់ឲ្យប្រព្រឹត្តបទល្មើស (ប៉ុន្តែក្រោយមក ករណីនេះត្រូវបានលើកលែងចោទប្រកាន់វិញ តាមការស្នើរបស់លោក

នាយករដ្ឋមន្ត្រី) ហើយត្រូវបានគេព្យួរការងារ។ អ្នករាយការណ៍ពិសេស លើកទឹកចិត្តដល់រដ្ឋាភិបាល ឲ្យបើកកិច្ចប្រជុំពិគ្រោះយោបល់ដែលមានការចូលរួមច្រើន ជាមួយភាគីពាក់ព័ន្ធទាំងឡាយ លើសេចក្តីព្រាងច្បាប់នេះ។

## ង. *អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*(ECCC)

៣៣. អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលហៅកាត់ថា(ECCC) បានសំរេចសមិទ្ធិផលធំធេង នៅក្នុងអំឡុងពេលសរសេររបាយការណ៍នេះ។ បន្ទាប់ពីការកាត់ទោស កាំង ហ្គិច អ៊ីវ ហៅ "ឌុច" ក្នុងខែកក្កដា ឆ្នាំ២០១០ មក សាលាក្តីនេះបានបន្តដំណើរនីតិវិធីករណីទីពីរ(សំណុំរឿង ០០២) លើជនជាប់ចោទឈ្មោះ នួន ជា, អៀង សារី, អៀង ធារិទ្ធ និង ខៀវ សំផន។ សំណុំរឿងនេះ ត្រូវបានបញ្ជូនទៅជំនុំជម្រះក្នុងខែមករា ឆ្នាំ២០១១។ សវនាការបឋមបានប្រព្រឹត្តទៅក្នុងខែមិថុនា ឆ្នាំ២០១១ ហើយការជំនុំជម្រះត្រូវបានគ្រោងធ្វើនៅពាក់កណ្តាលឆ្នាំ២០១១។ ទន្ទឹមនេះដែរ អង្គជំនុំជម្រះតុលាការកំពូលនៃសាលាក្តីនេះ បាននិងកំពុងពិនិត្យលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿងរបស់ "ឌុច" ។ អង្គជំនុំជម្រះ បានបើសវនាការលើដីកាបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា និងអង្គភាពមេធាវី ក្នុងខែមីនា ឆ្នាំ២០១១។ គេរំពឹងថា អង្គជំនុំជម្រះនឹងចេញសាលក្រមរបស់ខ្លួនក្នុងពេលប៉ុន្មានខែបន្ទាប់ពីនោះ។

៣៤. សកម្មភាពការងាររបស់តុលាការក្នុងបញ្ហានេះ បន្តផ្តល់ជាឧទាហរណ៍ដ៏សំខាន់មួយដល់វិស័យជាតិគ្រប់គ្រងប្រព័ន្ធយុត្តិធម៌របស់កម្ពុជា ស្របតាមបទដ្ឋានអន្តរជាតិស្តីពីការកាត់សេចក្តីប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌។ ជាពិសេស ភាពរីកចំរើននៃសំណុំរឿង ០០២ គឺជាប្រការមួយគួរឲ្យស្ងើចសរសើរ។ ម្យ៉ាងវិញទៀត សាលាក្តីនេះបន្តបើកទ្វារទទួលសាធារណៈជនកម្ពុជា ធ្វើទស្សនកិច្ចសិក្សាអំពីការងាររបស់ខ្លួន និង បានទទួលទស្សនិកជនចំនួន ៣២.០០០ នាក់ គិតតែក្នុងឆ្នាំ២០១០ ប៉ុណ្ណោះ។ ទន្ទឹមនឹងនេះ អង្គភាពគាំទ្រជនរងគ្រោះ បន្តបើកវាទិកាសាធារណៈថ្នាក់តំបន់នៅទូទាំងប្រទេសកម្ពុជា ដែលវេទិកាមួយចំនួនកំពុងធ្វើនៅខេត្តបាត់ដំបង កំពត និង កំពង់ឆ្នាំង នៅពេលធ្វើរបាយការណ៍នេះ។ នៅក្នុងអំឡុងពេលសរសេររបាយការណ៍នេះ សំណុំរឿង ០០៣ និងសំណុំរឿង ០០៤ នៅមិនទាន់មានភាពប្រាកដប្រជានៅឡើយទេ។

៣៥. ក្នុងខែធ្នូ ឆ្នាំ២០១០ អ្នករាយការណ៍ពិសេសបានសរសេរលិខិតមួយច្បាប់ទៅលោកនាយករដ្ឋមន្ត្រី អំពីសារសំខាន់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(ECCC) ធ្វើ

ជាគំរូមួយដល់សហគមន៍អន្តរជាតិអំពីការសន្យារបស់កម្ពុជា ក្នុងការធានាគណនេយ្យភាពចំពោះអំពើសាហាវយង់ឃ្នងក្នុងអតីតកាល និង អំពីការលើកកំពស់ឯករាជ្យនៃអង្គតុលាការ និងនីតិរដ្ឋ។ លោកបានគូសបញ្ជាក់ឡើងវិញថា លោកសង្ឃឹមថាការកាត់សេចក្តីនៅសាលាក្តីខ្មែរក្រហម(ECCC) និងផ្តល់ផលវិជ្ជមានក្នុងការពង្រឹងឯករាជ្យភាពនៃអង្គតុលាការ និងដើតតួនាតីជាកាតាលីករណ៍សំរាប់រាជរដ្ឋាភិបាល ក្នុងការដោះស្រាយបញ្ហានីទណ្ឌភាព និងពន្លឿនដល់ដំណើរការកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។

## IV. *តួនាទី និង ប្រសិទ្ធភាពរបស់សភាក្នុងការការពារសិទ្ធិមនុស្ស*

### ក. *រចនាសម្ព័ន្ធទូទៅរបស់សភា*

៣៦. កម្ពុជាអនុវត្តប្រព័ន្ធទ្វិកសភានិយមដែលសភាមានពីរថ្នាក់ ព្រឹទ្ធសភា និងរដ្ឋសភា។ រដ្ឋសភាមាន១២៣ អាសនៈ និងព្រឹទ្ធសភាមាន៦១ អាសនៈ។ នីតិកាលរបស់រដ្ឋសភាមានកំណត់ ៥ ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលដែលរដ្ឋសភាថ្មីចូលកាន់តំណែង។ សមាជិកសភាត្រូវបានជ្រើសតាំងសំរាប់មណ្ឌលបោះឆ្នោតចំនួន២១ សមាមាត្រទៅនឹងចំនួនខេត្តទាំងអស់នៅកម្ពុជា ដោយការបោះឆ្នោតតាមប្រព័ន្ធតំណាងសមាមាត្រ។

៣៧. នីតិកាលរបស់ព្រឹទ្ធសភាមានកំណត់៦ ឆ្នាំ។ ក្នុងចំណោមសមាជិកព្រឹទ្ធសភាទាំង ៦១ រូប មាន៥៧ រូប ត្រូវបានជ្រើសតាំងដោយក្រុមប្រឹក្សាឃុំ/សង្កាត់ សមាជិកពីររូប ត្រូវបានរដ្ឋសភាជ្រើសតាំង ហើយសមាជិកព្រឹទ្ធសភា ២ រូបទៀត ត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ។ សភាទាំងពីរថ្នាក់នេះ មានរចនាសម្ព័ន្ធគណៈកម្មការអចិន្ត្រៃយ៍មួយ ហើយគណៈកម្មការអចិន្ត្រៃយ៍នីមួយៗមានប្រាំបួនគណៈកម្មការ។ គណៈកម្មការទាំងអស់នេះ មានប្រធានគណៈកម្មការ ដែលជាសមាជិកគណបក្សកាន់អំណាច (គណបក្សប្រជាជនកម្ពុជា)។

៣៨. សភាកម្ពុជាបានប្រឈមមុខនឹងវិបត្តិដូចគ្នាខាងស្ថាប័ន និងរចនាសម្ព័ន្ធ ដែលប្រទេសនេះទាំងមូលបានជួបប្រទះក្នុងរយៈពេលប្រមាណជា៤០ ឆ្នាំកន្លងមកហើយ។ ដូចជាប្រព័ន្ធយុត្តិធម៌ សភា និងវប្បធម៌សភានិយម បានត្រូវបានកសាងឡើងវិញចាប់ពីបាត់ដៃទទេ ក្រោយពីមានការបំផ្លិចបំផ្លាញជាប្រព័ន្ធនៃស្ថាប័នប្រជាធិបតេយ្យទាំងអស់នៅក្នុងសម័យខ្មែរក្រហម។ រចនាសម្ព័ន្ធសភា និងសេវារូបវ័ន្តរបស់សភានាពេលបច្ចុប្បន្ននេះមានសភាពល្អដូចជាសេវារូបវ័ន្តរបស់ប្រទេសកំពុងអភិវឌ្ឍដទៃទៀតដែរ ហើយក្នុង

ចំណុចភាគច្រើនមានសភាពល្អលើសពីមធ្យមភាគទៅទៀត។ ស្រដៀងគ្នានឹងសភានៃប្រទេសភាគច្រើនទៀតដែរ សភាកម្ពុជាមានមុខនាទីជាតំណាងរាស្ត្រ នីតិកម្ម និង ត្រួតពិនិត្យលើការអនុវត្តន៍របស់អង្គនីតិប្រតិបត្តិ។

៣៩. សកម្មភាពការងាររបស់សភាទាំងមូល ចាប់ពីការងារធ្វើច្បាប់រហូតដល់ការពិនិត្យលើការអនុវត្តន៍ការងាររបស់អង្គនីតិប្រតិបត្តិ គ្របដណ្តប់លើវិសាលភាពទាំងមូលនៃសិទ្ធិមនុស្ស។ សកម្មភាពទាំងនេះមានឥទ្ធិពលផ្ទាល់ទៅលើលទ្ធភាពរបស់ប្រជាជន ក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន។ ក្នុងគោលដៅផ្តោតលើបញ្ហាសិទ្ធិមនុស្ស ទាំងរដ្ឋសភា ទាំងព្រឹទ្ធសភាតែរៀងៗខ្លួន បានបង្កើតគណៈកម្មការមួយក្នុងគោលបំណងនេះ។ គណៈកម្មការសិទ្ធិមនុស្សព្រឹទ្ធសភា ដែលរហូតមកទល់ពេលនេះ បានទទួលពាក្យបណ្តឹងច្រើនជាង ៣០០ បណ្តឹងអំពីការរំលោភសិទ្ធិមនុស្សពីប្រជាពលរដ្ឋទូទៅ និងបានទទួលការឆ្លើយតបច្រើនជាង១០០ ករណី ពីក្រសួងមន្ទីរនានាដែលពាក់ព័ន្ធ។ គណៈកម្មការនេះបានធ្វើការស៊ើបអង្កេតករណីប្រមាណជា៥០ ករណី នៅក្នុងអំឡុងពេលប៉ុន្មានឆ្នាំថ្មីៗនេះ។ គណៈ កម្មការសិទ្ធិមនុស្សរដ្ឋសភាបានទទួលពាក្យបណ្តឹងសរុប ១១៥៨ បណ្តឹងពីសាធារណៈ ជនទូទៅក្នុងចន្លោះឆ្នាំ២០០៦ និងឆ្នាំ២០១០ ករណីបណ្តឹងភាគច្រើនបំផុតទាក់ទងនឹងទំនាស់ដីធ្លី។ បន្ទាប់បានទទួលពាក្យបណ្តឹងទាំងនេះ គណៈកម្មការសិទ្ធិមនុស្សបានចាត់វិធានការលើករណីមួយចំនួនធំ និងបានសរសេរលិខិតទៅក្រសួងមន្ទីរពាក់ព័ន្ធនានា។ គណៈកម្មការបានទទួលការឆ្លើយតបសរុបប្រមាណជា ២៥០ ចន្លោះពីឆ្នាំ២០០៦ និងឆ្នាំ២០១០។ គណៈកម្មការក៏បានពិនិត្យសេចក្តីព្រាងច្បាប់ផ្សេងៗទាក់ទងនឹងការ លើកស្ទួយ និងការការពារសិទ្ធិមនុស្សផងដែរ។

៤០. ទន្ទឹមនឹងអ្នករាយការណ៍ពិសេស មានការពេញចិត្តចំពោះសមិទ្ធិផលដែលកម្ពុជាសំរេចបាន ក្នុងការបង្កើតការអនុវត្តន៍របបសភានិយមនៅក្នុងអំឡុងពេលមួយដ៏ខ្លីនេះក្តីក៏នៅមានចំណុចខ្វះខាតមួយចំនួនក្នុងការងាររបស់សភាជាទូទៅ ហើយជាពិសេសការងាររបស់រដ្ឋសភា។

## ខ. *ប្រសិទ្ធភាពរបស់ព្រឹទ្ធសភា*

៤១. និយាយជារួម ការអនុវត្តន៍ការងារសភានៅក្នុងព្រឹទ្ធសភាមានភាពជឿនលឿន និងមានលក្ខណៈសមស្របច្រើនជាងទៅនឹងគោលការណ៍ប្រជាធិបតេយ្យ និងតម្លាភាព។ មានចំណុចល្អៗជាច្រើនដែលរដ្ឋសភា អាចរៀនសូត្រពីការអនុវត្តន៍ការងាររបស់ព្រឹទ្ធសភា។ គណៈកម្មការផ្សេងៗរបស់ព្រឹទ្ធសភា រាប់ទាំង គណៈកម្មការសិទ្ធិមនុស្ស

អាចបំពេញការទទួលខុសត្រូវរបស់ខ្លួនមានប្រសិទ្ធភាពច្រើនជាង។ គណៈកម្មការទាំងប្រាំបួនរបស់ព្រឹទ្ធសភា បានបំពេញបេសកកម្មស្វែងរកការពិតចំនួន២៩ លើកក្នុងមួយឆ្នាំគិតជាមធ្យមភាគ។ ទោះជាដូច្នេះក្តី ព្រឹទ្ធសភាបានទទួលស្គាល់ខ្លួនឯងថា "ត្រូវបានគេទុកពេលវេលាឲ្យខ្លីពេក សំរាប់ធ្វើការពិនិត្យពិច័យលើអត្ថបទច្បាប់"។ ម្យ៉ាងវិញទៀត ការពិគ្រោះយោបល់លើសេចក្តីព្រាងច្បាប់ផ្សេងៗជាមួយអ្នកដែលពាក់ព័ន្ធនានា "នៅមិនទាន់មានតម្លាភាពច្រើនណាស់ណាទេ"។[2]

## គ. *ប្រសិទ្ធភាពរបស់រដ្ឋសភា*

៩២. មុខងារសំខាន់មួយរបស់សភា គឺការធ្វើច្បាប់ថ្មី និង ការធ្វើវិសោធនកម្មច្បាប់ដែលមានស្រាប់។ មុខងារសំខាន់មួយទៀត គឺការពិនិត្យលើការអនុវត្តន៍ការងាររបស់ស្ថាប័ននីតិប្រតិបត្តិ តាមរយៈការឃ្លាំមើលសកម្មភាពការងាររបស់ស្ថាប័ននេះ និងចាប់ឲ្យទទួលខុសត្រូវ(គណនេយ្យភាព) ចំពោះសកម្មភាពការងាររបស់ខ្លួន ដើម្បីការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋ ប្រឆាំងនឹងការរំលោភអំណាចដែលអាចកើតមាន។ មុខងារសំខាន់ទីបីរបស់សភា គឺភាពជាតំណាងដែលតម្រូវឲ្យសមាជិកសភា (តំណាងរាស្ត្រ) ចុះធ្វើការតាមមណ្ឌលបោះឆ្នោតរបស់ខ្លួន ដើម្បីពិភាក្សាស្វែងយល់ឲ្យបានច្រើនថែមទៀត និង តំណាងឲ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋនៅក្នុងសភា។

៩៣. និយាយជារួម សេចក្តីព្រាងច្បាប់ជាច្រើនត្រូវបានគេប្រញាប់ឆ្លងសភា ដោយមិនបានធ្វើការជជែកដេញដោលត្រឹមត្រូវ។ ប្រព័ន្ធគ្រប់គ្រងការអនុម័តច្បាប់ក្នុងរដ្ឋសភាមានលក្ខណៈតឹងតែង ដែលស្តែងឲ្យឃើញតាមរយៈការអនុវត្តន៍ថា ការកែប្រែកម្រត្រូវបានគេទទួលយកណាស់នៅក្នុងតំណាក់កាលណាមួយនៃដំណើរការនេះ។ នេះបង្ហាញឲ្យឃើញពីប្រសិទ្ធភាពរបស់រដ្ឋសភានៅមានកំរិតនៅឡើយ ក្នុងការពិនិត្យពិច័យច្បាប់ទាំងឡាយដែលស្ថាប័ននីតិប្រតិបត្តិបានរៀបចំតាក់តែងឡើង។ ទន្ទឹមនឹងរដ្ឋសភាបានអះអាងអំពីមុខងារឯករាជ្យរបស់ខ្លួន ដោយការបញ្ជូនសេចក្តីព្រាងច្បាប់ស្តីពីបាតុកម្មដោយសន្តិវិធីត្រឡប់ទៅគណៈរដ្ឋមន្ត្រីវិញនៅដើមឆ្នាំ២០០៨ក្តី ក៏មានច្បាប់សំខាន់ៗមួយចំនួនផ្សេងទៀត ដូចជា ក្រមព្រហ្មទណ្ឌ ច្បាប់ប្រឆាំងអំពើពុករលួយ និង ច្បាប់អស្សាមិករណ៍ត្រូវបានរដ្ឋសភាអនុម័តស្ទើរតែមិនមានការជជែកដេញដោល គ្មានការកែប្រែ និង មានការពិគ្រោះយោបល់តិចតួច ឬគ្មានទាល់តែសោះ និងស្ថិតក្នុងរង្វង់ពេលវេលាមួយដ៏ខ្លី។

[2] អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា របាយការណ៍មួយស្តីពីការវាយតំលៃខ្លួនឯងអំពីព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីរយៈពេល ១០ ឆ្នាំ នៃការប្រតិបត្តិការ និងការអភិវឌ្ឍន៍ (ភ្នំពេញ ខែមីនា ឆ្នាំ ២០១១) ទំព័រ ២៩

ម្យ៉ាងវិញទៀត សេចក្តីព្រាងច្បាប់ជាច្រើនដែលបានអនុម័តកាលពីពេលកន្លងទៅថ្មីៗនេះ (បទបញ្ញានិងអនុក្រិត្យខ្លះ) មាននិន្នាការទៅរកការធ្វើឲ្យតូចចង្អៀតដល់វិសាលភាពសិទ្ធិមនុស្ស។ សមត្ថភាពរបស់សភាកម្ពុជា ក្នុងការរារាំង ឬបញ្ឈប់ស្ថាប័ននីតិប្រតិបត្តិ មិនឲ្យអនុវត្តដូចនេះ គឺនៅមានកំរិតនៅឡើយ។

៩៤. ឧបសគ្គសំខាន់មួយ គឺការខ្វះវប្បធម៌មួយដែលសភាប្រព្រឹត្តទៅយ៉ាងរលូន។ សញ្ញាណនៃគោលការណ៍សេរីនិយម និងពហុបក្ស ដែលបានតំកល់ក្នុងរដ្ឋធម្មនុញ្ញ ត្រូវបានតាក់តែងឡើង ក្នុងគោលដៅធានាលំហរសំរាប់ឲ្យប្រជាពលរដ្ឋគ្រប់រូប ចូលរួមក្នុងដំណើរការប្រជាធិបតេយ្យូបនីយកម្ម និង ការកសាងជាតិ។ ទោះជាដូច្នេះក្តី អវត្តមានវប្បធម៌នៃពិភាក្សាជជែកដេញដោល និងឆន្ទះនយោបាយ ក្នុងជំរុញឲ្យមានបរិយាកាសងាយស្រួលសំរាប់កិច្ចសន្ទនាប្រកបដោយន័យស្ថាបនា និងការពន្លឿនដល់ដំណើរការប្រជាធិបតេយ្យូបនីយកម្មក្នុងសង្គម។ វិធានអនុវត្តន៍មួយចំនួនរបស់សភាបាននិងកំពុងបង្កើតឲ្យមាន ប៉ុន្តែវាទំនងជាត្រូវប្រើពេលវេលាច្រើនទៀត ដើម្បីទទួលយកសេចក្តីត្រូវការសំរាប់មតិប្រឆាំងមានប្រសិទ្ធភាព។ បញ្ញត្តិមួយចំនួននៃបទបញ្ជាផ្ទៃក្នុងរបស់សភាមិនសម្រួលដល់លំហរសំរាប់សំលេងប្រឆាំងឡើយ។ មានចន្លោះប្រហោងផងដែរ ផ្នែកចំណេះដឹង និងជំនាញ ក្នុងចំណោមសមាជិកសភា និង បុគ្គលិកសភាវិជ្ជាជីវៈ ដែលគុណវឌ្ឍ និង ជំនាញរបស់ពួកគាត់បង្ហាញពីកង្វះការបណ្តុះបណ្តាលច្បាប់ជាមូលដ្ឋាន។ នេះបានក្លាយជាឧបសគ្គដល់សមត្ថភាពរបស់សមាជិកសភា ក្នុងការអនុវត្តន៍តួនាទីភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព។ ជារួម សមាជិកសភាកម្ពុជាមិនបានប្រើប្រាស់អំណាចរបស់ខ្លួនមានប្រសិទ្ធភាពក្នុងការពិនិត្យលើការអនុវត្តន៍ការងាររបស់ស្ថាប័ននីតិប្រតិបត្តិ និងចាប់ឲ្យស្ថាប័ននីតិប្រតិបត្តិទទួលខុសត្រូវ (គណនេយ្យភាព) ចំពោះសកម្មភាពការងាររបស់ខ្លួន។

៩៥. មិនមានគណៈកម្មការណាមួយរបស់សភា មានប្រធានដែលជាសមាជិកមួយនៃគណបក្សប្រឆាំង ឬគណបក្សភាគតិចណាមួយឡើយ។ សភានៅប្រទេសជាច្រើនមានទំលាប់អនុវត្ត ដោយមានសមាជិកមួយរូបនៃគណបក្សប្រឆាំង ឬគណបក្សភាគតិចណាមួយធ្វើជាប្រធានគណៈកម្មាធិការ ឬគណៈកម្មការជាក់លាក់មួយចំនួនក្នុងសភា។ នេះជាទំលាប់អនុវត្តមួយជាអន្តរជាតិ ដើម្បីឲ្យមានភាពជាតំណាងបែបសមធម៌ ឬសមាមាត្រនៃតំណាងរាស្ត្រគណបក្សប្រឆាំងនៅក្នុងគណៈកម្មការ ឬគណៈកម្មាធិការសភាពដូចនេះ។ ប៉ុន្តែករណីដូចនេះមិនមានទេនៅកម្ពុជា។ គណបក្សប្រឆាំង ឬគណបក្សភាគតិចនានាមានមុខនាទីមួយសំខាន់ក្នុងការចាប់ឲ្យរដ្ឋាភិបាលទទួលខុសត្រូវ(គណនេយ្យភាព) ក្នុង

សកម្មភាពការងាររបស់ខ្លួន។ គណបក្សប្រឆាំងទាំងនោះអាចផ្តល់ជាជំរើសគោលនយោបាយផ្សេងៗដាក់ស្នើទៅរដ្ឋាភិបាល និងសាធារណៈជនពិនិត្យពិចារណា។ អាស្រ័យហេតុនេះ គណបក្សប្រឆាំងនានា គួរត្រូវបានធានាសិទ្ធិក្នុងការដាក់ស្នើចំណុចផ្សេងៗសំរាប់ការជជែកដេញដោលលើគោលនយោបាយនិងនីតិកម្ម ក្នុងរបៀបវារៈរបស់សភា ព្រមទាំងទុកពេលវេលាស្មើគ្នាសំរាប់ពិនិត្យពិចារណាលើចំណុចរបៀបវារៈនេះ ហើយមិនគួរបដិសេធសំលេងណាមួយដែលតំណាងឲ្យម្ចាស់ឆ្នោតឡើយ។

៤៦. បន្ទាប់ពីគណបក្សកាន់អំណាច គឺគណបក្សប្រជាជនកម្ពុជា(CPP) បានឈ្នះឆ្នោតច្រើនជាងពីរភាគបីនៃអាសនៈនៅក្នុងរដ្ឋសភានៅក្នុងការបោះឆ្នោតសកល កាលពីខែកក្កដា ឆ្នាំ២០០៨[3] រដ្ឋសភាមានមុខងារ និងភារកិច្ចជាសភាមួយសមស្របសំរាប់ជជែកលើបញ្ហាផ្សេងៗនេះ ទំនងជាកំពុតែងចុះអន់ថយ។ ក្នុងចំណោមលិខិតទាំងអស់ដែលគណបក្សប្រឆាំងនៅក្នុងសភាបានផ្ញើជូនរដ្ឋាភិបាល មានលិខិត ២៣% ប៉ុណ្ណោះ ដែលទទួលបានការឆ្លើយតបវិញ ហើយ ៩០% នៃការឆ្លើយតបទាំងនោះទទួលបានជាងពីមួយខែក្រោយថ្ងៃផ្ញើចេញ។ រដ្ឋមន្ត្រីនានា កម្រនឹងចូលរួមប្រជុំនៅក្នុងសភាណាស់ ដើម្បីឆ្លើយនឹងសំណួររបស់សមាជិកសភា។ សមាជិកសភាក្នុងគណបក្សប្រឆាំងដ៏ធំមួយ និងគណបក្សភាគតិចមួយចំនួនទៀត ស្ទើរតែត្រូវគេឈប់ឲ្យចូលរួមក្នុងដំណើរការធ្វើច្បាប់ទៅហើយ។ គណបក្សប្រជាជនកម្ពុជា(CPP) បានកាន់កាប់អាសនៈច្រើនជាងពីរភាគបីនៅក្នុងរដ្ឋសភា មាននិន្នាការ(ទំនោរ) ទៅរកការមិនអើពើអំពីតួនាទីនយោបាយរបស់គណបក្សដទៃផ្សេងទៀត។ គណបក្សប្រឆាំង និងគណបក្សភាគតិចជាច្រើនទៀត រអ៊ូរទាំថាពួកគាត់ត្រូវបានគណបក្សកាន់អំណាចចាត់ទុកខ្លួនជាសត្រូវរបស់រដ្ឋ ច្រើនជាងជាដៃគូខាងនយោបាយដែលមានទស្សនៈផ្សេងគ្នា។

៤៧. ទោះបីជារដ្ឋធម្មនុញ្ញត្រូវឲ្យមានការបោះឆ្នោតជាសំងាត់ សំរាប់ការសំរេចផ្សេងៗដែលសំខាន់ៗនៅក្នុងសភាក្តី ក៏ការសំរេចសំខាន់ៗភាគច្រើននៅក្នុងរដ្ឋសភាត្រូវបានធ្វើឡើងផ្អែកលើប្រព័ន្ធបោះឆ្នោតអនុម័តយកសំលេងភាគច្រើន(bloc voting) និងដោយការលើកដៃ (show of hands) ធ្វើដូច្នេះរដ្ឋាភិបាលអាចសំគាល់ឃើញសមាជិកសភាណាខ្លះដែលបោះឆ្នោតប្រឆាំងនឹងញត្តិរបស់រដ្ឋាភិបាល។ ដូច្នេះហើយ សមាជិកសភាជា

[3] គណបក្សប្រជាជនកម្ពុជា(CPP) បានឈ្នះឆ្នោត៩០ អាសនៈក្នុងចំណោះអាសនៈទាំងអស់ ១២៣ នៅក្នុងរដ្ឋសភា គណបក្សសម រង្ស៊ីចំនួន ២៦ អាសនៈ គណបក្សសិទ្ធិមនុស្សចំនួនបីអាសនៈ គណបក្សនរោត្តមរណឫទ្ធិពីរ អាសនៈ និងគណបក្សហ៊្វុនស៊ីនប៉ិចចំនួនពីរអាសនៈ។

បុគ្គលអាចនឹងខ្វះសេចក្តីក្លាហានក្នុងការបោះឆ្នោតដោយឯករាជ្យ ឬជំទាស់ទៅនឹងសំណើផ្សេងៗរបស់រដ្ឋាភិបាល។

៤៨. នៅពេលដែលគណបក្សប្រជាជនកម្ពុជា(CPP) បានទទួលសំលេងគាំទ្រភាគច្រើនពីរភាគបីនៅក្នុងការបោះឆ្នោតសកលកាលពីឆ្នាំកន្លងទៅ រដ្ឋសភាបានអនុម័តបទបញ្ជាផ្ទៃក្នុងក្នុងខែកញ្ញា ឆ្នាំ២០០៨ ដែលបង្រួញឲ្យតូចចង្អៀតដល់វិសាលភាពនៃការចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងសភា ពីគណបក្សប្រឆាំង និងគណបក្សភាគតិចដទៃទៀត។ ជាអាទិ៍ ប្រការ ៤៨ និង ប្រការ ៥៥ នៃបទបញ្ជាផ្ទៃក្នុង តម្រូវឲ្យសមាជិកសភាអង្គុយជាក្រុមមួយដែលមានចំនួនដប់នាក់ ក្រុមនីមួយៗត្រូវជ្រើសតាំងប្រធាន និងអនុប្រធានក្រុមរបស់ខ្លួន។ នេះមានន័យថា សមាជិកសភាដែលមកពីគណបក្សភាគតិចដែលមានសមាជិកសភារបស់ខ្លួនតិចជាងដប់នាក់ ត្រូវចូលរួមក្រុមជាមួយសមាជិកសភាមកពីគណបក្សផ្សេងៗទៀត។

៤៩. អាស្រ័យហេតុនេះ សមាជិកសភាជាបុគ្គលម្នាក់ៗ មិនអាចនិយាយនៅក្នុងសភាដោយមិនបានឆ្លងកាត់ប្រធានក្រុមមួយរូប និងដោយមិនបានទទួលការអនុញ្ញាតពីប្រធានរដ្ឋសភាឡើយ។ បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុងនេះ មានឥទ្ធិពលដល់ការបដិសេធសមាជិកសភាមកពីគណបក្សភាគតិចទាំងឡាយ ដែលមានអាសនៈតិចជាងដប់ ក្នុងការបំពេញតួនាទីរបស់ខ្លួនប្រកបដោយអត្ថន័យនៅក្នុសភា និងអនុវត្តហួសវិសាលភាពនៃនីតិរបស់សភាដែលបានបញ្ជាក់យ៉ាងច្បាស់ក្នុងមាត្រា៩៦ នៃរដ្ឋធម្មនុញ្ញ។ ជាអាទិ៍បច្ចុប្បន្ន គណបក្សសិទ្ធិមនុស្ស មានសមាជិកតែបីរូបប៉ុណ្ណោះនៅក្នុងសភា។ ដោយហេតុថាសមាជិកសភាទាំងនេះមិនបានចូលរួមក្រុមណាមួយនោះ ព្រោះចង់រក្សាឯករាជ្យភាពរបស់ខ្លួន ទើបពួកគាត់គ្មានឱកាសបំពេញមុខងារដូចសមាជិកសភាធម្មតានៅក្នុងការជជែកដេញដោលក្នុងសភា។ សំរាប់ហេតុផលដូចបានគូសបញ្ជាក់ខាងលើ មុខងាររបស់សភាត្រូវបានកំរិតកំណត់ក្នុងពិនិត្យលើសកម្មភាពការងាររបស់ស្ថាប័ននីតិប្រតិបត្តិ។

## ឃ. *ការការពារសេរីភាពក្នុងការនិយាយស្តីរបស់សមាជិកសភា*

៥០. សភាគឺជាដួងព្រលឹងនៃលិទ្ធិប្រជាធិបតេយ្យ។ ដើម្បីឲ្យលិទ្ធិប្រជាធិបតេយ្យមួយដំណើរការបានត្រឹមត្រូវ សមាជិកសភាគ្រប់រូបគួរតែអាចប្រើប្រាស់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ នៅក្នុងពេលបំពេញតួនាទីភារកិច្ចផ្លូវការរបស់ខ្លួន។ នេះគឺជាលក្ខខណ្ឌគ្រឹះមួយសំរាប់សមាជិកសភាមួយរូប អាចបញ្ចេញមតិ ឬទស្សនៈរបស់ខ្លួនដោយគ្មានការ

ភ័យខ្លាច។ លិទ្ធិប្រជាធិបតេយ្យគឺសំដៅដល់កិច្ចសន្ទនា និងការជជែកដេញដោលលើរាល់បញ្ហាទាំងឡាយដែលមានសារសំខាន់សំរាប់ប្រទេសជាតិ ហើយការមានជាពិសេសក្នុងករណីនៃសភាដែលបើតាមនិយមន័យនៃពាក្យនេះគឺ ជាសាលប្រជុំដ៏ធំមួយ(សភា) ដែលសមាជិកទាំងអស់អាចធ្វើការជជែកដេញដោលដោយសេរីលើបញ្ហាទាំងឡាយដែលមានសារសំខាន់សំរាប់ប្រទេសជាតិ។ ដោយសារតែហេតុនេះហើយ ទើបសមាជិកសភាគ្រប់រូប ទទួលបានអភ័យឯកសិទ្ធិសភា។ ទោះជាយ៉ាងណាក៏ដោយ បច្ចុប្បន្នបញ្ញត្តិមួយនៃបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភាមិនផ្តល់ភាពងាយស្រួលឲ្យសមាជិកសភាគ្រប់រូបអាចប្រើប្រាស់សិទ្ធិសេរីភាពក្នុងការនិយាយស្តីទេ នៅពេលព្យាយាមឲ្យអង្គនីតិប្រតិបត្តិទទួលខុសត្រូវ (គណនេយ្យភាព) ចំពោះសកម្មភាពការងាររបស់ខ្លួន និងក្នុងការការពារសិទ្ធិប្រជាពលរដ្ឋម្ចាស់ឆ្នោត (រាស្ត្រដែលគាត់តំណាងឲ្យ)។ នៅពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ វិសាលភាពសំរាប់សមាជិកសភានៅកម្ពុជា ចូលរួមក្នុងការជជែកដេញដោលក្នុងសភាបានមានការរិតត្បិត និងមានការដកហូតអភ័យឯកសិទ្ធិរបស់សមាជិកសភាមួយចំនួន សូម្បីតែការសំដែងមតិអំពីបញ្ហាទាំងឡាយដែលមានសារសំខាន់សំរាប់ប្រទេសជាតិក្តី។ ម្យ៉ាងវិញទៀត សមាជិកសភាភាគច្រើន មិនត្រូវបានគេផ្តល់ឱកាសឲ្យឡើងធ្វើបទបង្ហាញណាមួយដើម្បីការពារខ្លួនឡើយ ដែលការអនុវត្តន៍បែបនេះ ផ្ទុយទៅនឹងគោលការណ៍ជាមូលដ្ឋានស្តីពីយុត្តិធម៌ធម្មជាតិ។ លិទ្ធិប្រជាធិបតេយ្យមួយដែលដំណើរត្រឹមត្រូវ តម្រូវឲ្យមានការពិនិត្យប្រកបដោយប្រសិទ្ធភាពលើសកម្មភាពការងាររបស់អង្គនីតិប្រតិបត្តិ និង ពិនិត្យលើសំលេងភាគច្រើន។

៥១. មាត្រា៨០ នៃរដ្ឋធម្មនុញ្ញ ធានាការពារអភ័យឯកសិទ្ធិរបស់តំណាងរាស្ត្រគ្រប់រូបដើម្បីអាចប្រើប្រាស់សេរីភាពក្នុងការនិយាយស្តី ដើម្បីឲ្យពួកគាត់អាចពិនិត្យពិច័យនិងរិះគន់លើការដឹកនាំរបស់រដ្ឋមន្ត្រីនានា និង សកម្មភាពការងារ និង គោលនយោបាយផ្សេងៗរបស់ស្ថាប័ននីតិប្រតិបត្តិ។ មាត្រា៤ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រចែកអភ័យឯកសិទ្ធិសភាជាពីរផ្នែកៈ អភ័យឯកសិទ្ធិដាច់ខាតរបស់តំណាងរាស្ត្រ និង អភ័យឯកសិទ្ធិដោយប្រៀបរបស់តំណាងរាស្ត្រ។ អភ័យឯកសិទ្ធិដាច់ខាតរបស់តំណាងរាស្ត្រធានាចំពោះការបញ្ចេញយោបល់ ឬការបញ្ចេញមតិក្នុងការអនុម័តច្បាប់ដោយរដ្ឋសភាហើយអភ័យឯកសិទ្ធិដោយប្រៀបរបស់តំណាងរាស្ត្រ ធានាមិនឲ្យមានការចោទប្រកាន់ការ ចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួនតំណាងរាស្ត្រណាមួយ។ លុះត្រាតែមានការលើកអភ័យឯកសិទ្ធិសភាជាមុនសិន ទើបតំណាងរាស្ត្រណាបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនឹងអាចអនុញ្ញាតបើកឲ្យធ្វើការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬ ការឃុំខ្លួនតាមច្បាប់ និងនីតិវិធីបាន។

៥២. ពាក្យស្នើសុំលើកអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រណាមួយ ដែលគេអះអាងថា បានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ គួរតែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជាអ្នកដាក់ស្នើទៅប្រធានរដ្ឋសភា។ ប្រធានរដ្ឋសភាអាចដកអភ័យឯកសិទ្ធិសភារបស់តំណាងរាស្ត្រណាមួយបាន តាមរយៈការបោះឆ្នោតយកសំលេងពីរភាគបីនៃសមាជិករដ្ឋសភាទាំងមូល។ ទោះជាដូច្នេះក្តី ច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ មិនផ្តល់ឱកាសណាមួយឲ្យតំណាងរាស្ត្រដែលមានបញ្ហា ធ្វើបទបង្ហាញឬលើកជាអំនាស់អំនាង ដើម្បីការពារខ្លួនឡើយ។ ដូច្នេះ តំណាងរាស្ត្រមួយរូប ត្រូវបានគេដកហូតអភ័យឯកសិទ្ធិសភារបស់ខ្លួន ដោយមិនបានផ្តល់ឱកាសបើកសវនាការមួយត្រឹមត្រូវឡើយ។ គណបក្សកាន់អំណាច ដោយសារតែខ្លួនមានសំលេងពីភាគបីស្រាប់ហើយនោះ បានប្រើអំណាចរបស់ខ្លួនដកហូតអភ័យឯកសិទ្ធិសភារបស់តំណាងនៃគណបក្សប្រឆាំង ដោយមិនផ្តល់ឱកាសឲ្យពួកគាត់លើកអំនាស់អំនាងការពារខ្លួនឡើយ។

៥៣. ម្យ៉ាងវិញទៀត បញ្ញត្តិខ្លះច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ទំនងជាចែងលើសអំពីសេរីភាពក្នុងការបញ្ចេញមតិដែលបានធានាការពារចំពោះតំណាងរាស្ត្រ តាមរយៈអភ័យឯកសិទ្ធិសភានៅក្នុងរដ្ឋធម្មនុញ្ញ។ មាត្រា៨០ ចែងថាតំណាងរាស្ត្ររូបណាក៏ដោយ មិនត្រូវបានចោទប្រកាន់ ឃាត់ខ្លួន ឬឃុំខ្លួន ដោយហេតុពីបានសំដែងយោបល់ ឬបញ្ចេញមតិក្នុងការបំពេញមុខងាររបស់ខ្លួនសោះឡើយ។ ទោះជាដូច្នេះក្តី មាត្រា៥ នៃច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ធ្វើឲ្យកិច្ចការពារនេះតូចចង្អៀត ដោយចែងថា ប្រសិនជាតំណាងរាស្ត្រណាមួយ ត្រូវគេរកឃើញថា បានរំលោភនាំឲ្យប៉ះពាល់ដល់កិត្តិយសរបស់បុគ្គលដទៃ ដល់ទំនៀមទំលាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិ អភ័យឯកសិទ្ធិសភារបស់គាត់អាចត្រូវបានលើក (មិនបានកំណត់ច្បាស់ថាតើសកម្មភាពទាំងនេះ ធ្វើឡើងសំរាប់ហេតុផលអ្វីនោះឡើយ)។ បញ្ញត្តិដូចនេះ អាចត្រូវបានគេប្រើប្រាស់មិនត្រឹមត្រូវ ប្រសិនជាមិនកំណត់ឲ្យបានច្បាស់លាស់ និង ភ្ជាប់កិច្ចធានាការពារឲ្យបានគ្រប់គ្រាន់ទេនោះ។ នៅក្នុងបរិបទនេះ គួរកត់សំគាល់ថា រដ្ឋសភានៅមិនទាន់ប្រគល់ឲ្យវិញនូវ អភ័យឯកសិទ្ធិសភារបស់សមាជិកមួយរូបនៃគណបក្សប្រឆាំងទេ បើទោះជាសមាជិកសភារូបនោះ បានបង់ប្រាក់ពិន័យតាមការបង្គាប់របស់តុលាការរួចហើយក្តី តាមបទចោទប្រកាន់ពីការបរិហាកេរ្តិ៍លោកនាយករដ្ឋមន្ត្រី ដែលប្រាក់ពិន័យនោះ ត្រូវបានគេកាត់ចេញពីប្រាក់បៀវត្សរ៍របស់លោកស្រីជាសមាជិកសភាមួយរូប។[4]

---

[4] សមាជិកសភាដែលកំពុងបំរើការងារបានប្រកាសនៅក្នុងសន្និសិទសារព័ត៌មានមួយ ដែលបានរៀបចំធ្វើនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៩

គ្មានភាពច្បាស់លាស់នៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈតំណាងរាស្ត្រ ចែងអំពីវិធី ឬ របៀបផ្តល់អភ័យឯកសិទ្ធិសភាឲ្យវិញ ប្រសិនជាសមាជិកសភារូបនោះ មិនត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគារ ឬ ត្រូវបានលើកលែងចោទប្រកាន់ទេ។

៥៤. អ្នករាយការណ៍ពិសេសយល់ឃើញថា ការបរិហារកេរ្តិ៍ និងការផ្សាយព័ត៌មានមិនពិត គួរតែត្រូវបានដកចេញពីទោសបញ្ញត្តិព្រហ្មទណ្ឌទាំងស្រុងពីប្រព័ន្ធច្បាប់នៅកម្ពុជា។ គណបក្សទាំងនោះ មិនអាចធ្វើការដោយសេរីបាននោះទេ ប្រសិនបើពួកគាត់ប្រឈមនឹងការគំរាមកំហែងដោយបណ្តឹងព្រហ្មទណ្ឌពីបទបរិហារកេរ្តិ៍ ការផ្សាយព័ត៌មានមិនពិត ឬការញុះញង់ នៅពេលដែលពួកគាត់រិះគន់ ដែលមិនត្រឹមតែចំពោះកម្មវិធី និងគោលនយោបាយផ្សេងៗរបស់រដ្ឋាភិបាលប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងចំពោះការដឹកនាំរបស់រដ្ឋមន្ត្រីនានា។ ដោយសារតែវប្បធម៌នៃការភ័យខ្លាចនេះហើយ ទើបជាសាធារណៈជនទូទៅ ឬសូម្បីតែមន្ត្រីរាជការស៊ីវិលទាំងឡាយ ទំនងជាមានការរារែកចិត្តក្នុងការចូលរួមប្រជុំជាសាធារណៈដែលគណបក្សប្រឆាំងភាគច្រើនបានរៀបចំឡើង។ ហេតុដូច្នេះ អ្នករាយការណ៍ពិសេសមានកង្វល់អំពីការរួមតូចចង្អៀតនៃលំហរនយោបាយនៅកម្ពុជា ដែលបង្កការងាយស្រួលដល់ការលើកកំពស់ និងការពង្រឹងវប្បធម៌ប្រជាធិបេយ្យនៅកម្ពុជា។

## V. *ក្រុមប្រឹក្សាធម្មនុញ្ញ សិទ្ធិមនុស្ស និង សភា*

៥៥. ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបានបង្កើតឡើង ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យលើច្បាប់ទាំងឡាយដែលសភាបានអនុម័ត ដើម្បីធ្វើឲ្យប្រាកដថាច្បាប់ទាំងនោះ ស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញ និងបញ្ញត្តិដែលចែងអំពីសេរីភាព និងសិទ្ធិជាមូលដ្ឋានដែលបានធានាការពារដោយរដ្ឋធម្មនុញ្ញ និងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងឡាយ ដែលកម្ពុជាបានផ្តល់សច្ចាប័នទទួលយក។ ក្រុមប្រឹក្សានេះមានសមាសភាពឥស្សរជនល្បីៗមួយចំនួន ដែលបានជ្រើសសម្រាំងចេញពីមនុស្សគ្រប់ស្រទាប់វណ្ណៈ។ នេះជាសមាសធាតុថ្មីមួយនៃរដ្ឋធម្មនុញ្ញកម្ពុជា និងជាការបំពេញបន្ថែមដ៏សំខាន់មួយពីលើស្ថាប័នទាំងឡាយ ដែលបានបង្កើតឡើង ក្នុងគោលដៅពង្រឹងលិទ្ធិប្រជាធិបតេយ្យ។

ថាលោកស្រីនឹងដាក់ពាក្យបណ្តឹងមួយពីបទបរិហាកេរ្តិ៍ប្រឆាំងនឹងលោកនាយករដ្ឋមន្ត្រីចំពោះសន្ទរកថាប្រមាថមើលងាយលើរូបលោកស្រី។ បណ្តឹងរបស់លោកស្រីប្រឆាំងនឹងលោកនាយករដ្ឋមន្ត្រីត្រូវបានលើកលែងចោទប្រកាន់ និងសេចក្តីសំរេចតំកល់បណ្តឹងឧទ្ធរណ៍ អភ័យឯកសិទ្ធិសភារបស់លោកស្រីត្រូវបានលើក ហើយលោកស្រីត្រូវបានគេរកឃើញថាមានពិរុទ្ធភាពពីការបរិហារកេរ្តិ៍។ តុលាការបានសំរេចឲ្យលោកស្រីបង់ប្រាក់ពិន័យ ដែលត្រូវបានគេកាត់ចេញពីប្រាក់បៀវត្សរ៍របស់លោកស្រីជា សមាជិកសភាមួយរូប។

ក្រុម ប្រឹក្សាធម្មនុញ្ញ គឺជាស្ថាប័នមួយដែលមានអំណាច ដែលយ៉ាងហោចណាស់ ដូចដែល មានចែងក្នុងអត្ថបទច្បាប់ដែរ។ ស្ថាប័ននេះ មានតួនាទីពិនិត្យច្បាប់ផ្សេងៗក្រោយពីសភា បានអនុម័តរួច ដែលនៅក្នុងប្រទេសជាច្រើន ស្ថាប័ននេះមិនមានទេ។ ស្ថាប័ននេះ មាន មុខងារដូចតុលាការធម្មនុញ្ញ ឬតុលាការកំពូលនៃប្រទេសមួយដែរ ដែលមានអំណាច ប្រកាសធម្មនុញ្ញភាពនៃច្បាប់ណាមួយ ជាស្ថាប័នមួយដែលរដ្ឋធម្មនុញ្ញបានផ្តល់ *អំណាច លើសលុប* នៅក្នុងប្រទេសជាច្រើន។ ក្រុមប្រឹក្សាធម្មនុញ្ញមានសមាសភាពប្រធានមួយ រូប និងសមាជិកចំនួនប្រាំបីរូប។ ក្រុមប្រឹក្សានេះ មិនអាចពិនិត្យធម្មនុញ្ញភាពនៃច្បាប់ ណាមួយតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ឡើយ។ មានតែព្រះមហាក្សត្រ ប្រធានព្រឹទ្ធ សភា ប្រធានរដ្ឋសភា នាយករដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភាចំនួនមួយភាគបួន និងតំណាង រាស្ត្រមួយភាគដប់ ឬប្រធានតុលាការកំពូល អាចបញ្ជូនសេចក្តីព្រាងច្បាប់ទៅឲ្យក្រុម ប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ដែលសភាបានអនុម័ត។

៥៦. ក្នុងការប្រើប្រាស់អំណាចរបស់ខ្លួន ក្រុមប្រឹក្សាធម្មនុញ្ញកម្ពុជាបានចេញសេចក្តី សំរេចមួយចំនួនរបស់ខ្លួនដែលមានវិសាលភាពទូលំទូលាយ ដូចជាសេចក្តីសំរេចរបស់ ក្រុមប្រឹក្សាធម្មនុញ្ញអំពីច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ក្នុងខែកក្កដា ឆ្នាំ២០០៧[5] ដែលយោងលើបទដ្ឋានអន្តរជាតិនានា។ ទោះជាដូច្នេះក្តី វិសាលភាពនៃការងាររបស់ខ្លួន នៅមានកំរិត ដោយហេតុថា ប្រជាពលរដ្ឋជាឯកត្តបុគ្គលមិនមានឱកាសតវ៉ាដោយផ្ទាល់ អំពីធម្មនុញ្ញភាពនៃច្បាប់ដែលសភាបានអនុម័តឡើយ។ ប្រជាពលរដ្ឋកម្ពុជា ត្រូវតែឆ្លង កាត់តំណាងរាស្ត្ររបស់ខ្លួន ដើម្បីបញ្ជូនញត្តិនោះទៅក្រុមប្រឹក្សាធម្មនុញ្ញ ហើយតំណាង រាស្ត្រទំនងជាកម្រងនឹងអនុវត្តអំណាចរបស់ខ្លួន ដើម្បីដាក់សំណើទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យច្បាប់ណាមួយ ដែលពួកគាត់(តំណាងរាស្ត្រ) បានអនុម័តពីដើមដំបូងនោះ ណាស់។

[5] ច្បាប់នេះ ត្រូវបានសភាអនុម័តក្នុងឆ្នាំ២០០២ ដែលបានដកហូតទាំងពីរ ទាំងឆន្ទានុសិទ្ធិរបស់ចៅក្រម ដែលកាលពីពេល កន្លងមក
ចៅក្រមត្រូវពិចារណាលើអាយុរបស់ជនល្មើសសំរាប់ជាមូលដ្ឋាននៃស្ថានសំរាលទោស និងទាំង កាតព្វកិច្ចដែលចៅក្រមត្រូវបញ្ឈប់ការកាត់ទោសពន្ធនាគារណាមួយចំពោះបុគ្គលដែលមានអាយុក្រោម១៨ ឆ្នាំ ។ នៅក្នុងឆ្នាំ២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញ បានសំរេចថាច្បាប់នេះ ស្របតាមរដ្ឋធម្មនុញ្ញ ប៉ុន្តែត្រូវតែផ្អែកលើមូល ដែលថាច្បាប់នេះគ្មានគោលដៅធ្វើនិរាករណ៍ដល់កិច្ចការពារចំពោះជនល្មើសជាអនីតិជន ដូចមានចែងក្នុង ច្បាប់ព្រហ្មទណ្ឌអន្តរកាល (ច្បាប់អ៊ុនតាក់) ដោយសារបញ្ញត្តិនេះបានរំលោភទាំងលើរដ្ឋធម្មនុញ្ញ ទាំងលើ អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ (CRC) ។ ក្រុមប្រឹក្សាធម្មនុញ្ញបានបំភ្លឺថែមទៀតនៅក្នុងសេចក្តីសំរេចរបស់ ខ្លួនថា សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិទាំងឡាយ ដែលព្រះរាជាណាចក្រកម្ពុជា គឺជាភាគី
គឺជាផ្នែកមួយនៃច្បាប់កម្ពុជា ហើយចៅក្រមត្រូវអនុវត្តសន្ធិសញ្ញាទាំងអស់នោះដោយផ្ទាល់នៅក្នុងតុលាការ។ សូមមើល សេចក្តីសំរេចលេខ A/HRC/7/56.

៥៧. មានតែភាគីក្តីជាប្រជាពលរដ្ឋឯកជនប៉ុណ្ណោះ ដែលនៅចំពោះមុខតុលាការអាចលើកយកបញ្ហាអធម្មនុញ្ញភាពនៃបទប្បញ្ញត្តិច្បាប់ ឬសេចក្តីសម្រេចរបស់ស្ថាប័នរដ្ឋនានា រួមមានព្រះរាជក្រឹត្យ អនុក្រឹត្យ និងសេចក្តីសម្រេចរដ្ឋបាលផ្សេងៗ ប៉ុន្តែវាស្រេចតែលើតុលាការកំពូលក្នុងការបញ្ជូនបញ្ហាបែបនោះ ទៅកាន់ក្រុមប្រឹក្សាធម្មនុញ្ញ។ តុលាការកំពូលពុំទាន់បានអនុវត្តសិទ្ធិនេះនៅឡើយ ទោះបីជាតុលាការនេះត្រូវបានស្នើសុំឲ្យធ្វើដូច្នោះ ក្នុងរឿងក្តីមួយចំនួននាពេលថ្មីៗនេះក៏ដោយ។ ក្រុមប្រឹក្សាធម្មនុញ្ញមានករណីតិចតួចបំផុតដើម្បីធ្វើការពិចារណា។ ការអនុម័តច្បាប់មួយចំនួន ព្រមទាំងវាទប្បដិវាទ ជុំវិញទង្វើមួយចំនួនរបស់សភា ឬបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន គួរតែត្រូវបានពិនិត្យឡើងវិញដោយក្រុមប្រឹក្សាធម្មនុញ្ញ។ ទោះបីជាមាត្រា១៤០ នៃរដ្ឋធម្មនុញ្ញផ្តល់អំណាចយ៉ាងជាក់ជាក់ដល់ក្រុមប្រឹក្សានេះក្នុងការពិនិត្យបញ្ហាផ្ទៃក្នុងរបស់រដ្ឋសភា និងព្រឹទ្ធសភា មុនពេលប្រកាសឲ្យប្រើក៏ដោយ ក៏ក្រុមប្រឹក្សានេះពុំបានបំពេញមុខងារនេះដោយបានម៉ឺងម៉ាត់ និងសកម្មតាមការគួរនោះទេ។ ក្រុមប្រឹក្សានេះហាក់ដូចជាពុំបានពិនិត្យធម្មនុញ្ញភាពនៃបទប្បញ្ញត្តិវាទប្បដិវាទនានា នៅក្នុងបទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា និងព្រឹទ្ធសភា មុនពេលបទបញ្ជាទាំងនោះត្រូវបានប្រកាសឲ្យប្រើនោះទេ។ ឧត្តមានុភាពនៃគណៈបក្សប្រជាជនកម្ពុជា នៅក្នុងយន្តការរដ្ឋនេះ ហាក់ដូចជានាំឲ្យក្រុមប្រឹក្សានេះធ្វើការរឹតត្បិតលើការបញ្ចេញមតិរបស់ខ្លួនឯង។

៥៨. ទោះបីជាក្រុមប្រឹក្សាធម្មនុញ្ញពុំមានស្ថិតនៅក្នុងប្រព័ន្ធ និងរចនាសម្ព័ន្ធរបស់តុលាការ និងសភាក៏ដោយ ប៉ុន្តែវាជាស្ថាប័នខ្ពស់បំផុតសម្រាប់ធ្វើការពិនិត្យធម្មនុញ្ញភាពរបស់ច្បាប់នានា ដែលត្រូវបានអនុម័តដោយសភា។ មុខងាររបស់ក្រុមប្រឹក្សានេះមានលក្ខណៈជាតុលាការតែម្តង ហើយមានលក្ខណៈប្រហាក់ប្រហែលគ្នានឹងអំណាចនានាដែលអនុវត្តដោយយុត្តាធិការរបស់តុលាការកំពូល ឬតុលាការធម្មនុញ្ញរបស់ប្រទេសផ្សេងៗមួយចំនួន។ ដូច្នោះហើយ សមាជិកនៃក្រុមប្រឹក្សានេះ គួរតែមានសមាសភាពមកពីអ្នកច្បាប់ឯករាជបំផុតរបស់ប្រទេស ដែលត្រូវបានជ្រើសចេញមកពីចៅក្រមចូលនិវត្តន៍នានារបស់តុលាការកំពូល។

## VI. *សេចក្តីសន្និដ្ឋាន*

៥៩. អ្នករាយការណ៍ពិសេសមានការពេញចិត្តចំពោះកិច្ចសហប្រតិបត្តិការកំរិតល្អមួយជាមួយរាជរដ្ឋាភិបាល។ កិច្ចសន្ទនាជាមួយលោកនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រីនានា មានភាពស្និទ្ធស្នាល និងគ្មានការលាក់លៀម ហើយភាគីទាំងសងខាងបានព្រមព្រៀងគ្នា

បន្តកិច្ចសហប្រតិបត្តិការរបស់ខ្លួន។ ជំនួបប្រជុំដែលអ្នករាយការណ៍ពិសេសបានធ្វើឡើងជាមួយប្រធាន និងសមាជិករដ្ឋសភា និងព្រឹទ្ធសភា តំណាងគណបក្សនយោបាយ និងតំណាងសង្គមស៊ីវិលនានាបានទទួលលទ្ធផលប្រកបដោយផ្លែផ្កា។ អន្តរកម្មរបស់គាត់ដោយផ្ទាល់ជាមួយជនរងគ្រោះដោយអំពើរំលោភសិទ្ធិមនុស្សទាំងឡាយ បានធ្វើឲ្យគាត់យល់ដឹងអំពីភាពទន់ខ្សោយមួយចំនួនដែលនៅមានក្នុងការអនុវត្តន៍ច្បាប់ជាតិនិងបទដ្ឋានអន្តរជាតិនានានៅក្នុងប្រទេស។

៦០. អ្នករាយការណ៍ពិសេសមានកង្វល់អំពីលំហរតូចចង្អៀតសំរាប់ប្រជាពលរដ្ឋក្នុងការបញ្ចេញទស្សនៈរបស់ខ្លួនដោយសន្តិវិធី និងដោយគ្មានការភ័យខ្លាច រាប់ទាំងសកម្មជនទាំងឡាយក្នុងគណបក្សផ្សេងៗ។ លោកមានកង្វល់ជាពិសេសក្នុងបញ្ហានេះ អំពីការប្រើប្រាស់បណ្តឹងព្រហ្មទណ្ឌពីបទញុះញង់ប្រឆាំងនឹងអ្នកការពារសិទ្ធិមនុស្ស។ តាមទស្សនៈរបស់គាត់ តួអង្គនយោបាយ និង អង្គការសង្គមស៊ីវិលផ្សេងៗ គួរតែធ្វើការឆ្ពោះទៅបង្កើតបរិយាកាសមួយងាយស្រួលដល់មនុស្សគ្រប់រូបអនុវត្តសិទ្ធិមនុស្ស និងការអភិវឌ្ឍន៍សេដ្ឋកិច្ចសំរាប់ជាប្រយោជន៍ដល់មនុស្សគ្រប់រូប។

៦១. កម្ពុជាបានធ្វើដំណើរលើផ្លូវមួយដ៏វែង ចាប់តាំងពីមានការចុះកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសមក។ រដ្ឋធម្មនុញ្ញប្រជាធិបតេយ្យមួយត្រូវបានបង្កើតឲ្យមាន ហើយស្ថាប័នរដ្ឋជាច្រើនត្រូវបានបង្កើតឡើង ដើម្បីការពារនិងលើកស្ទួយសិទ្ធិមនុស្ស។ ទោះជាដូច្នេះក្តី ក្រសួងជាច្រើននេះ នៅមិនទាន់មានប្រសិទ្ធភាពក្នុងការការពារសិទ្ធិប្រជាជនរដ្ឋឡើយ។ អង្គតុលាការនៅតែជាស្ថានប័នមួយទន់ខ្សោយនៅឡើយ។ រឿងនយោបាយនៅតែត្រូវបានគេបញ្ជូនទៅដោះស្រាយនៅតុលាការហើយសមាជិកមួយចំនួននៃគណបក្សប្រឆាំងត្រូវបានតុលាការផ្តន្ទាទោសពីបទឧក្រិដ្ឋ ដែលបើផ្អែកតាមបទដ្ឋានប្រជាធិបតេយ្យអន្តរជាតិ ករណីរឿងដូចនេះ មិនអាចបង្កើតជាបទឧក្រិដ្ឋនោះទេ។

៦២. ការងារដែលសភាទូទៅ ជាពិសេសគណៈកម្មការជំនាញផ្សេងៗមានសមត្ថភាព ធ្វើបានសំរេចនៅកម្ពុជា គឺជារឿងមួយគួរឲ្យកោតសរសើរ។ ការងាររបស់គណៈកម្មការសិទ្ធិមនុស្សសភាពទាំងពីរបានធ្វើឲ្យមានការអបអរសាទរនិងលើកទឹកចិត្ត។ សរុបសេចក្តីទៅកម្ពុជាបានធ្វើការផ្លាស់ប្តូរមួយយ៉ាងធំសម្បើម ចាប់ពីរដ្ឋមួយដែលត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង រហូតដល់ការធ្វើច្បាប់ និងការបង្កើតស្ថាប័នផ្សេងៗ។ ទោះជាយ៉ាងណាក៏ដោយ កម្ពុជានៅមិនទាន់ជោគជ័យចូលដល់ដំណាក់កាលអនុវត្តច្បាប់ ដែលបានអនុម័ត

ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស និង ធ្វើឲ្យស្ថាប័នទាំងឡាយរបស់ខ្លួន ឯករាជ្យ មិនលំអៀង និង រឹងមាំ នៅឡើយទេ។

៦៣. បន្ទាប់ពីផ្តោតលើសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដូចជា សន្តិសុខស្បៀង និង ការអភិវឌ្ឍន៍ បច្ចុប្បន្ននេះ សង្គមកម្ពុជាកំពុងខិតខំជំរុញធ្វើឲ្យមានភាពជឿនលឿនឆាប់ រហ័សឈានទៅអនុវត្តសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ និងវិស័យសិទ្ធិមួយចំនួន ដូចជាសេរីភាព និងយុត្តិធម៌ និងការពង្រឹងវប្បធម៌សភានិយម។ ទោះជាដូច្នេះក្តី រដ្ឋាភិ បាលនៅមិនទាន់បង្កើនល្បឿនពេញទំហឹងនៅឡើយទេ ដើម្បីឲ្យមានការផ្លាស់ប្តូរមួយ ស្រដៀងនេះ។ គោលដៅរបស់រដ្ឋាភិបាលទាក់ទងនឹងបញ្ហាលិទ្ធិប្រជាធិបតេយ្យ និងសិទ្ធិ មនុស្សហាក់ដូចជាមិនសូវសកម្ម។ ជាលទ្ធផល ទោះជាបានបង្កើតឲ្យមានស្ថាប័នច្រើន ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្សក្តី ក៏មានស្ថាប័នជាច្រើនមិនមានប្រសិទ្ធភាពក្នុង ការបំពេញមុខងាររបស់ខ្លួនប្រកបដោយឯករាជ្យ មិនលំអៀង និងបានរឹងមាំឡើយ។ ការសន្យាភាគច្រើនដែលរដ្ឋាភិបាលបានធ្វើគឺមានតែនៅលើក្រដាសប៉ុណ្ណោះ។ ដូច្នេះអ្វី ដែលរដ្ឋាភិបាលត្រូវការធ្វើគឺការផ្លាស់ប្តូរផ្នត់គំនិតរបស់ខ្លួន និងឆន្ទៈនយោបាយ ដើម្បី ពន្លឿនដំណើរការប្រជាធិបតេយ្យូបនីយកម្ម និងការផ្សាភ្ជាប់លទ្ធិប្រជាធិបតេយ្យ និង សិទ្ធិមនុស្សទៅនឹងតំលៃសង្គម ដែលលើកស្ទួយ និងការពារសេចក្តីថ្លៃថ្នូររបស់បុគ្គល គ្រប់រូប និងការគោរពសិទ្ធិរបស់ពួកគាត់។

## VII. *អនុសាសន៍ផ្សេងៗ*

### ក. *ទិដ្ឋភាពទូទៅ - សភា*

៦៤. កម្ពុជា ត្រូវការការពន្លឿនថែមទៀត ដល់ដំណើរការប្រជាធិបតេយ្យូបនីយកម្មក្នុង ប្រទេស។ គួរតែមានឆន្ទៈមួយពិតប្រាកដ និងការខិតខំព្យាយាមធ្វើការផ្សះផ្សាបញ្ហាវិបត្តិ នយោបាយ ដើម្បីឲ្យតួអង្គគណបក្សទាំងអស់មានឱកាសស្មើគ្នា ក្នុងការចូលរួមជាវិភាគ ទាន ឬរួមចំណែកក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច និងនយោបាយរបស់ប្រទេសជាតិ និង ដំណើរការសភានិយម។ សិទ្ធិរបស់សមាជិកសភាទាំងអស់ចាប់ពីតំណាងរាស្ត្រមកពី គណបក្សដែលអាសនៈភាគច្រើន ដល់គណបក្សដែលមានអសសនៈភាគតិចក្នុងសភា អាចអនុវត្តតួនាទីភារកិច្ចរបស់ខ្លួន គួរតែត្រូវបានគោរពអនុវត្តតាម។

៦៥. រដ្ឋធម្មនុញ្ញកម្ពុជា កំណត់កាតព្វកិច្ចត្រូវរៀបចំធ្វើសមាជជាតិម្តងក្នុងមួយឆ្នាំ ក្រោមព្រះរាជបូជនីយកិច្ចរបស់ព្រះមហាក្សត្រ ដើម្បីអាចឲ្យប្រជាពលរដ្ឋទាំងអស់បានដឹងដោយផ្ទាល់អំពីបញ្ហាផ្សេងៗជាប្រយោជន៍ជាតិ និងដើម្បីលើកឡើងអំពីបញ្ហាជាកង្វល់ប្រាប់ឲ្យអាជ្ញាធរនៃស្ថាប័នសំខាន់ៗទាំងបីរបស់រដ្ឋ។ នេះជាករណីតែមួយគត់ និងជាបញ្ញត្តិថ្មីមួយនៃរបបប្រជាធិបតេយ្យបែបផ្ទាល់ ដែលអាចបង្កើតជាវេទិកាមួយសមស្របដើម្បីសំរេចការផ្សះផ្សានយោបាយជាតិ ការសើរើពិនិត្យអំពីការរីកចំរើនដែលសំរេចបានក្នុងលើកស្ទួយ និងការការពារសិទ្ធិមនុស្ស និងពង្រឹងអធិបតេយ្យភាពនៃប្រទេសជាតិ។ ដោយសារព្រះមហាក្សត្រមានព្រះរាជកិច្ចជាអ្នកធានាការពាររដ្ឋធម្មនុញ្ញ ព្រះមហាក្សត្រគួរតែមានសមត្ថភាពទទួលប្រជារាស្ត្រដែលចូលគល់ និងទទួលព័ត៌មានពីប្រជារាស្ត្រគ្រប់ស្រទាប់វណ្ណៈ។ ទោះជាយ៉ាងណាក៏ដោយ រហូតមកទល់ពេលនេះ មិនមានសមាជណាមួយត្រូវបានរៀបចំធ្វើនោះទេ។ សមាជគួរតែរៀបចំឡើងរៀងរាល់ឆ្នាំ ដូចបានកំណត់ក្នុងរដ្ឋធម្មនុញ។ ក្នុងចំណុចនេះ ច្បាប់អង្គការមួយស្តីពីសមាជជាតិ គួរតែត្រូវបានបង្កើតឡើង។

## ខ. *ការពង្រឹងសមត្ថភាព និង ការងាររបស់សភា*

៦៦. គណៈកម្មការសិទ្ធិមនុស្សក្នុងសភា គួរតែធ្វើការបញ្ជ្រៀបសិទ្ធិមនុស្ស ជាបញ្ហាពហុវិស័យមួយនិងធ្វើការផ្តោះទៅធានាការអនុវត្តន៍ច្បាប់ជាតិឲ្យស្របតាមបទដ្ឋានអន្តរជាតិ។

៦៧. គណបក្សប្រឆាំងទាំងឡាយ គួរតែចូលរួមយ៉ាងពេញទំហឹងនៅក្នុងសកម្មភាពការងាររបស់សភា ហើយសហការគ្នា ជាពិសេស ក្នុងការងាររបស់គណៈកម្មការនានារបស់រដ្ឋសភា។

៦៨. នីតិវិធីផ្ទៃក្នុងរបស់សភាជាទូទៅ ជាពិសេស នីតិវិធីផ្ទៃក្នុងរបស់រដ្ឋសភា គួរត្រូវបានពិនិត្យឡើងវិញ ដើម្បីលើកទឹកចិត្តឲ្យមានការបែងចែកអំណាច និងការទទួលខុសត្រូវប្រកបដោយភាពស្មើគ្នា ឬមានសមាមាត្រនៅក្នុងសកម្មភាពការងាររបស់សភា និងជាពិសេសក្នុងតួនាទីភាពជាអ្នកដឹកនាំនៅក្នុងគណៈកម្មការសភាផ្សេងៗ។

៦៩. នីតិវិធីសំរាប់ការដកហូតអភ័យឯកសិទ្ធិសភា និង ការដាក់ទណ្ឌកម្មខាងវិន័យប្រឆាំងនឹងសមាជិកក្នុងសម័យប្រជុំ គួរតែអនុវត្តស្របតាមគោលការណ៍យុត្តិធម៌ធម្មជាតិ បទដ្ឋានរដ្ឋធម្មនុញ្ញ និង សេរីភាពក្នុងការបញ្ចេញមតិ។

៧០. រដ្ឋាភិបាលគួរបង្កើនធនធានថែមទៀត លៃបំរុងសំរាប់សកម្មភាពការងារសភា ដើម្បីពង្រឹងសមត្ថភាពទូទៅ របស់សភាដែលជាស្ថាប័នមួយឯករាជ្យ និងមានប្រសិទ្ធភាព និងសមត្ថភាពរបស់សមាជិកសភាជាបុគ្គលរៀងៗខ្លួន ដើម្បីពិនិត្យពិច័យសេចក្តីព្រាងច្បាប់ ដែលរដ្ឋាភិបាលបានដាក់បញ្ជូនមក។

៧១. សភាជាទូទៅ ជាពិសេស រដ្ឋសភា គួរតែបង្កើនប្រសិទ្ធភាពរបស់ខ្លួន ក្នុងការពិនិត្យលើការងាររបស់ស្ថាប័ននីតិប្រតិបត្តិ និងចាប់ឲ្យស្ថាប័ននេះទទួលខុសត្រូវ (គណនេយ្យភាព) ចំពោះសកម្មភាពរបស់ខ្លួន។ គួរតែបង្កបរិយាកាសងាយស្រួលដល់សមាជិកសភាគ្រប់រូប លើកជាសំណួរដោយចំហរអំពីគោលនយោបាយ និង ការសំរេចផ្សេងៗរបស់គណបក្សរបស់ខ្លួនផ្ទាល់។ ក្នុងករណីនេះ គេគួរតែយល់ឲ្យបានច្បាស់ថា ក្នុងនាមជាតំណាងរាស្ត្រ ខ្លួនមានការទទួលខុសត្រូវជាក់លាក់មួយចំនួន លើសពីការទទួលខុសត្រូវដែលខ្លួនមាននៅក្នុងជួរនយោបាយទៅទៀត។

៧២. អគ្គលេខាធិការនៃសភាទាំងពីរ គួរតែជាបុគ្គលឯករាជ្យ និងមិនមែនជាសកម្មជនមួយរូប នៃគណបក្សនយោបាយណាមួយឡើយ។

៧៣. ការជ្រើសរើសមន្ត្រីសភាជាទូទៅ ជាពិសេស មន្ត្រីរដ្ឋសភា គួរតែបានធ្វើឡើងឈរលើមូលដ្ឋានគុណសម្បត្តិ និងតាមរយៈដំណើរការជ្រើសរើសមួយមានការប្រកួតប្រជែង និងមានតម្លាភាព។

៧៤. សេចក្តីព្រាងច្បាប់គួរតែបានបោះពុម្ពផ្សាយ សំរាប់ឲ្យមានការពិគ្រោះយោបល់ជាសាធារណៈ ជាពិសេស ជាសៀវភៅផ្សេងៗមានដូចជា រាជកិច្ចជាដើម។ រាជកិច្ចទាំងនេះគួរតែរក្សាឲ្យមានសំរាប់សាធារណជនអាចទាក់ទងរកបាន ។

៧៥. ច្បាប់មិនគួរត្រូវបានដាក់ឲ្យអនុវត្តឡើយ រហូតទាល់តែច្បាប់ទាំងនោះត្រូវបានចុះផ្សាយក្នុងរាជកិច្ច ។

៧៦. គណៈកម្មការសភាផ្សេងៗ គួរតែពិនិត្យឡើងវិញនូវរាល់បទបញ្ជាអនុវត្តន៍ច្បាប់ ឬសេចក្តីណែនាំផ្សេងៗដែលអនុម័តដោយរដ្ឋាភិបាល ដើម្បីធ្វើឲ្យប្រាកដថា បទបញ្ជា ឬសេចក្តីណែទាំងនោះ មិនចែងហួសវិសាលភាពនៃបញ្ញត្តិច្បាប់ដើមរបស់វាឡើយ។

៧៧. សេចក្តីតម្រូវជាសមាជិកនៃក្រុមមួយ ដែលមានសមាជិកសភាចំនួនដប់រូប ចូលរួមជជែកវែកញែកក្នុងសភា គួរតែរក្សាឲ្យមានតទៅទៀត ដើម្បីឲ្យសមាជិកសភាគ្រប់រូបមានឱកាសស្មើគ្នា ក្នុងការចូលរួមជជែកវែកញែកលើបញ្ហាផ្សេងៗ។

៧៨. គណបក្សប្រឆាំងសំខាន់មួយ គួរតែមានតួនាទីមួយត្រូវបំពេញប្រកបដោយន័យស្ថាបនា ក្នុងការតែងតាំងសមាជិកស្ថាប័នទាំងឡាយដែលបង្កើតឡើងដោយរដ្ឋធម្មនុញ្ញ ដូចជាគណៈកម្មការរៀបចំការបោះឆ្នោត ដើម្បីធ្វើឲ្យប្រាកដថា គណៈកម្មការទាំងនោះអាចប្រតិបត្តិការប្រកបដោយភាពឯករាជ្យ និង មិនលំអៀង។

៧៩. ក្នុងសភាជាច្រើនទៀតនៅជុំវិញពិភពលោក គណបក្សគ្រប់គ្រងអំណាច គួរតែអញ្ជើញគណបក្សប្រឆាំងផ្សេងៗធ្វើជាប្រធានគណៈកម្មការមួយចំនួន នៅក្នុងសភាជាទូទៅ ជាពិសេស នៅក្នុងរដ្ឋសភា។ ការធ្វើបែបនេះ អាចជួយពង្រឹងវប្បធម៌សភានិយមក៏ដូចជា វប្បធម៌មតិប្រឆាំង។ ករណីនេះ ធ្លាប់ត្រូវបានគេអនុវត្តនៅកម្ពុជាកាលពីមុន ប៉ុន្តែនៅពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ ដំណើរការនេះបានដើរថយក្រោយទៅវិញ។

៨០. គួរផ្តល់ភាពងាយស្រួលឲ្យម្ចាស់ឆ្នោតនៅតាមមណ្ឌលនានា អាចចូលជួបតំណាងរាស្ត្ររបស់ខ្លួន ដើម្បីឲ្យតំណាងរាស្ត្រទាំងនោះអាចការពារពួកគាត់បានកាន់តែប្រសើរឡើងថែមទៀត នៅក្នុងសភា។

## គ. *ការបង្កើនប្រសិទ្ធភាពរបស់ក្រុមប្រឹក្សាធម្មនុញ្ញ*

៨១. ក្រុមប្រឹក្សាធម្មនុញ្ញ គួរតែពិនិត្យមិនត្រឹមតែច្បាប់ទាំងឡាយដែលសភាបានអនុម័តប៉ុណ្ណោះទេ ប៉ុន្តែក្រុមប្រឹក្សាក៏គួរតែពិនិត្យផងដែរនូវបទបញ្ជាផ្ទៃក្នុងរបស់សភាជាទូទៅ ជាពិសេស បទបញ្ជាផ្ទៃក្នុងរបស់រដ្ឋសភា ដើម្បីធ្វើប្រាកដថា បញ្ញត្តិទាំងអស់ពិតជាស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញ បទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងគោលការណ៍នីតិរដ្ឋ រាប់ទាំងគោលការណ៍យុត្តិធម៌ធម្មជាតិផងដែរ។

៨២. ច្បាប់ណាក៏ដោយ ដែលសភាបានអនុម័ត ហើយដែលច្បាប់នោះមានជាប់ជំពាក់ដោយផ្ទាល់ដល់សិទ្ធិមនុស្ស គួរតែត្រូវបានបញ្ជូនដោយស្វ័យប្រវត្តិទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីពិនិត្យសិន មុននឹងដាក់ស្នើទៅព្រះមហាក្សត្រដើម្បីឡាយព្រះហស្ថលេខាប្រកាសឲ្យប្រើ។

៨៣. ការចូលជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ គួរតែបានបើកទូលាយ តួអង្គមួយចំនួនគេទទួលស្គាល់មិនមែនជាមន្ត្រីរាជការ មានជាអាទិ៍ សមាគមវិជ្ជាជីវៈមេធាវី និង សាស្ត្រាចារ្យច្បាប់ ព្រមទាំង ប្រជាពលរដ្ឋមួយចំនួន ក្នុងលក្ខខណ្ឌចង្អៀត និងក្នុងករណីពិសេស គួរតែមានសិទ្ធិចូលជាសមាជិកក្រុមប្រឹក្សានេះ។

៨៤. ក្រុមប្រឹក្សាគួរតែមានសមាសភាពអ្នកបញ្ញាវន្តច្បាប់ឆ្នើមបំផុត និងដែលឯករាជ្យរបស់ជាតិ ដែលជ្រើសសម្រាំងចេញពីក្នុងចំណោមចៅក្រមតុលាការកំពូលមួយចំនួនដែល ចូលនិវត្តន៍ សាស្ត្រាចារ្យច្បាប់ដែលល្បីឈ្មោះ និងមេធាវីជាន់ខ្ពស់ នៅក្នុងប្រទេស។

៨៥. ទម្លាប់តែងតាំងចូលកាន់មុខតំណែងជាសមាជិកក្រុមប្រឹក្សា ដោយគ្មានប្រវត្តិសវតាច្បាប់ និងមិនធ្លាប់បានបំរើការងាររដ្ឋរយៈពេលមួយវែងក្នុងវិស័យច្បាប់ និង ដោយឈរលើមូលដ្ឋាននិន្នាការគណបក្សនយោបាយរបស់ខ្លួន គួរតែឈប់ឲ្យមានតទៀត។

## ឃ. *សភា និង សេរីភាពខាងការបញ្ចេញមតិ*

៨៦. សភាគួរតែពិនិត្យឡើងវិញនូវបញ្ញត្តិក្រមព្រហ្មទណ្ឌថ្មី ក្នុងគោលដៅធ្វើប្រាកដថាក្រមនេះ ស្របតាមកំហិតដែលបានអនុញ្ញាតឲ្យដាក់ចំពោះសេរីភាពក្នុងការបញ្ចេញមតិក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។

៨៧. សភាគួរតែធានាការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិរបស់សមាជិករបស់ខ្លួនផ្ទាល់ និង ការពារអភ័យឯកសិទ្ធិសភារបស់ពួកគាត់។

## ង. *សេរីភាពខាងការបញ្ចេញមតិ*

៨៨. អង្គតុលាការ គួរធ្វើការបកស្រាយបញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ស្តីពីសេរីភាពក្នុងការបញ្ចេញមតិ។ ក្រសួងយុត្តិធម៌ គួរតែពឹងពាក់លើសហគមន៍អន្តរជាតិ រាប់ទាំងការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា ដើម្បីផ្តល់វគ្គបណ្តុះបណ្តាលផ្សេងៗដល់ចៅក្រម ព្រះរាជអាជ្ញា និងមេធាវី ក្នុងបញ្ហានេះ។

## ច. សិទ្ធិដីធ្លី

៨៩. រដ្ឋាភិបាល ត្រូវបានជំរុញលើកទឹកចិត្តឲ្យពិនិត្យមើលនិន្នាការបច្ចុប្បន្ននៃទំនាស់ដីធ្លីមួយចំនួន ដែលមិនទាន់ដោះស្រាយក្នុងប្រទេស និងដោះស្រាយលំនាំធ្ងន់ធ្ងរនៃអំពើហឹង្សា តាមរយៈការជួយសម្រួលឲ្យមានកិច្ចសន្ទនាគ្នា រវាងសហាគមន៍ដែលរងផលប៉ះពាល់ អាជ្ញាធរជាតិ អាជ្ញាធរខេត្ត អាជ្ញាធរមូលដ្ឋាន និងសហគ្រាស់ឯកជននានា។

៩០. រដ្ឋាភិបាល គួរតែចូលរួមពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយប្រជាពលរដ្ឋដែលរងផលប៉ះពាល់ដោយជំលោះដីធ្លី អំពីសំណងសមរម្យ ឬជំរើសផ្សេងៗមានដូចជាការផ្តល់លំនៅដ្ឋានសមរម្យ ប្រសិនជាអាចធ្វើបាន។ អាជ្ញាធរនានា គួរតែគោរព និងការពារសិទ្ធិប្រជាពលរដ្ឋទាំងនេះ រាប់ទាំងតាមរយៈការធានាថា ពួកគេមិនស្ថិតក្នុងកម្មវត្ថុនៃការប្រើប្រាស់កំលាំងហួសហេតុ ការឃាយី និងការបំភិបំភ័យ ដែលពួកគេអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនស្តីពីបាតុកម្មដោយសន្តិវិធី ហើយថាការចោទប្រកាន់ពីបទបរិហារកេរ្តិ៍ ការផ្សាយព័ត៌មានពិត និងការញុះញង់ មិនត្រូវបានធ្វើតាមទំនើងចិត្តឡើយ។

៩១. រដ្ឋាភិបាល ត្រូវបានផ្តល់ប្រឹក្សាយោបល់ឲ្យបង្កើតតម្លាភាពច្រើនថែមទៀត ក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច និងការចុះកិច្ចព្រមព្រៀងដីធ្លីជាមួយមន្ត្រីរដ្ឋាភិបាល ឬសហគ្រាសឯកជននានា និងសូមជំរុញលើកទឹកចិត្តឲ្យពង្រឹងសមត្ថភាពនិងឯករាជ្យភាពនៃប្រព័ន្ធតុលាការ គណៈកម្មការសុរិយោដី និងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី (NALDR)ដើម្បីឲ្យស្ថាប័នទាំងនេះអនុវត្តគណៈនេយ្យភាព ភាពមិនលំអៀង និង ប្រសិទ្ធភាព ថែមទៀត ក្នុងការដោះស្រាយទំនាស់ផ្សេងៗ។

៩២. រដ្ឋាភិបាល ត្រូវបានស្នើយ៉ាងទទូចឲ្យពង្រឹងការអនុវត្តន៍បញ្ញត្តិដែលមានស្រាប់នៃច្បាប់ភូមិបាលឆ្នាំ២០០១ ដែលហាមប្រាមការជ្រៀតជ្រែករំខានលើដីជនជាតិដើមភាគតិច និងពន្លឿនសន្ទុះនៃការចុះបញ្ជីដី ដើម្បីឲ្យជនជាតិដើមភាគតិចទទួលបានប័ណ្ណកម្មសិទ្ធិសមូហភាព។ រដ្ឋាភិបាលគួរតែអនុវត្តវិធានការការពារជាបណ្តោះអាសន្នលើដីទាំងអស់ ដែលសហាគមន៍ជនជាតិដើមភាគតិចទាំងឡាយកំពុងរស់នៅ រហូតដល់ដំណើរការចុះបញ្ជីដីចប់សព្វគ្រប់ ហើយពួកគាត់ទទួលបានប័ណ្ណកម្មសិទ្ធិរួចសិន។

៩៣. នៅពេលចូលរួមដោះស្រាយបញ្ហាដីធ្លី ទាំងជាមួយរដ្ឋាភិបាលកម្ពុជា ទាំងជាមួយម្ចាស់ដីផ្សេងៗ រដ្ឋាភិបាលបរទេស និងអង្គការពាណិជ្ជកម្មអន្តរជាតិនានា គួរតែចងចាំក្នុងចិត្តថាខ្លួនមានការទទួលខុសត្រូវមួយតាមច្បាប់អន្តរជាតិ ក្នុងការគោរពសិទ្ធិរបស់ប្រជាជនកម្ពុជា។ ការគាំទ្រការប្រើប្រាស់មន្ត្រីប្រតិបត្តិច្បាប់ប្រដាប់អាវុធឲ្យធ្វើការបណ្តេញ

ដោយខុសច្បាប់ គឺជាការអនុវត្តន៍ផ្ទុយទៅនឹងច្បាប់អន្តរជាតិ ហើយគួរតែចាត់ទុកថាជាទង្វើមួយខុសច្បាប់ផងដែរនៅកម្ពុជា៕

------------ END ----------

*ការបកប្រែក្រៅផ្លូវការ*